រ៉ឹម.រ៉ឺន
សាស្ត្រាចារ្យ សាលាគរុវិជ្ជា

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

# សៀវភៅសិក្សា លោកនីតិ

## បឋមសិក្សា

សមុច្ច័យគរុកោសល
រក្សាសិទ្ធិ

R. 6 9-10-56

គ.១៩៦.១៣៧

អ៊ិច-វ៉ែន

សាស្ត្រាចារ្យសាលាគរុវិជ្ជា

# សៀវភៅសិក្សា
# លោកនីតិ

បឋមសិក្សា
គ្រប់ថ្នាក់

សម្ព័យគរុកោសល

# អារម្ភកថា

គោលបំណងរបស់ខ្ញុំ មិនមែនចង់សរសេរសៀវភៅអធិប្បាយឲ្យបានអស់សេចក្ដីពីលោកនីតិនោះទេ ឬក៏សរសេរសៀវភៅទុកជាស្នាដៃនោះក៏ទេដែរ ។ ដែលធ្វើសៀវភៅនេះគ្រាន់តែជាជំនួយរបស់លោកគ្រូទាំងឡាយដែលតែងត្អូញត្អែរថាគ្មានអ្វីនឹងបង្រៀនលោកនីតិសោះ ។

មួយទៀតសៀវភៅនេះ សំរាប់តែប្រើប្រាស់នៅបឋម-សិក្សាប៉ុណ្ណោះ គឺសំរាប់បង្រៀនក្មេងតូច ៗ ដូច្នេះការដឹងជ្រៅជ្រះនូវច្បាប់លោកនីតិ មិនជាសំខាន់ប៉ុន្មានទេ ខ្ញុំចង់ស្រង់តែគោលការណ៍ដើមនៃលោកនីតិមកបង្ហាញក្មេង ដើម្បីឲ្យដឹងថាហេតុម្ដេចបានជាគេប្រតិបត្តិដូច្នោះ ហេតុអ្វីបានជាគេធ្វើដូច្នេះនៅក្នុងស្រុកយើងសព្វថ្ងៃ ។

លោកគ្រូទាំងអស់ នឹងឃើញថា មេរៀននីមួយ ៗ មានពីរផ្នែក៖ ផ្នែកសំនួរនឹងផ្នែកបង្ងការណ៍ ។ ផ្នែកសំនួរជា

គ្រឿងសំរាប់លោកគ្រូ យកទៅប្រើប្រាស់ក្នុងសិក្ខាបរិវប្ពន-(préparation de classe) ឬសំរាប់ឲ្យសិស្សរិះរកឆ្លើយដោយខ្លួនឯង មុនពេលពន្យល់ ឬក្រោយពេលពន្យល់ក៏បាន ។ ឯផ្នែកថ្លែងការណ៍វិញ ជាគ្រឿងជំនួយដល់គ្រូសំរាប់ផ្សំបញ្ចូលសេចក្ដីអធិប្បាយពន្យល់ក្នុងថ្នាក់ ។ ដូច្នេះសៀវភៅនេះកើតឡើងដើម្បីឆ្លើយនូវសេចក្ដីត្រូវការប្រើប្រាស់នៃគ្រូទាំងឡាយប៉ុណ្ណោះទេ មិនបានផ្ដល់នូវគោលបំណងគរុកោសលឲ្យបានត្រឹមត្រូវសោះឡើយ ។

# តើបង្រៀនលោកនីតិយ៉ាងដូចម្ដេច?

របៀបបង្រៀនលោកនីតិមិនខុសគ្នាពីរបៀបបង្រៀនចរិយាសាស្ត្រប៉ុន្មានទេ ។ គោលបំណងនៃការសិក្សាខាងចរិយាសាស្ត្រគឺចង់ឲ្យក្មេងកាន់អាកប្បកិរិយាត្រឹមត្រូវនៅក្នុងក្រុមញាតិក៏ដោយ ក្នុងសាលាក៏ដោយឬនៅតាមផ្លូវក៏ដោយ ហើយថែមទាំងចង់បណ្ដុះមនោសញ្ចេតនាល្អក្នុងសន្ដានចិត្តសិស្សផង ។ ចំណែកខាងការសិក្សាលោកនីតិវិញក៏ចង់ឲ្យក្មេងដែលជាពលរដ្ឋមួយនៅថ្ងៃក្រោយ អាចនឹងសម្រួលអាកប្បកិរិយាវាទៅតាមរបៀបរៀបរយរបស់សង្គមដែលវាសុខចិត្តរស់នៅ ។ បើនិយាយឲ្យខ្លី ការសិក្សាលោកនីតិ នឹងការសិក្សាចរិយាសាស្ត្រមានគោលបំណងតែមួយ គឺធ្វើឲ្យក្មេងចេះសម្របអាកប្បកិរិយាវា ឲ្យស្របនឹងអាកប្បកិរិយាបុគ្គលឯទៀតដែលរស់នៅជាមួយគ្នា ដើម្បីនឹងបានសន្តិភាពក្នុងសង្គមញាតិ, ក្នុងសង្គមសាលា ក្នុងសង្គមជាតិនិងក្នុងសង្គមអន្តរជាតិ ។

គោលបំណងសិក្សាទាំងពីរផ្នែកនេះមិនមែនបង់ឲ្យក្មេងចេះចាំអ្វីច្រើនទេ គឺគ្រាន់តែលត់ចិត្តវាឲ្យហូរ ទៅតាមគន្លងដែលយើងយល់ថាអាចនឹងនាំបរមសុខដល់មនុស្សទាំងអស់គ្នាប៉ុណ្ណោះ ៗ នៅក្នុងសង្គមយើងឥឡូវនេះ គោលបំណងរបស់ការសិក្សាបរិយាសាស្ត្រយើងនឹងធ្វើយ៉ាងដូចម្តេច ឲ្យក្មេងទម្លាប់ប្រតិបត្តិគោលការណ៍ដូចតទៅនេះ ៖

— ឲ្យសិស្សស្រឡាញ់ញាតិសន្តានរបស់វា ;

— ឲ្យវាស្រឡាញ់មិត្តភក្តិនៅសាលា ;

— ឲ្យវាយល់ថាសាមគ្គីគ្នានឹងគ្នា មានប្រយោជន៍ធំក្នុងលោកយើង ហើយឲ្យវាពេញចិត្តបង្សាមគ្គីនេះឲ្យមាំមួន ៗ

— ឲ្យវាមានចិត្តស្រឡាញ់ការងារដាដពាប ;

គោលការណ៍ខាងលោកនីតិវិញមានដូចតទៅនេះ ៖

— កុមារទាំងអស់ត្រូវយល់ថា យើងរស់នៅក្នុងសង្គមគឺនៅជាមួយនឹងបុគ្គលឯទៀត ៗ ជាច្រើន ហើយម្នាក់ ៗ ត្រូវរស់

នៅឲ្យបានសុខសាន្តត្រានស្មើៗ គ្នា;

- ម្នាក់ៗត្រូវជួយរៀបរយសង្គមនេះឲ្យសុខស្រួលដោយចាត់តាំងយ៉ាងហ្មត់ចត់ នូវអ្នកដំណាងរបស់យើង ដើម្បីឲ្យជួយបំពេញកិច្ចការជាប្រយោជន៍ទូទៅ;

- ត្រូវទំដាក់ប្រយោជន៍ទូទៅឲ្យនៅលើប្រយោជន៍ផ្ទាល់ខ្លួនដោយគោរពច្បាប់;

- កុមារត្រូវស្គាល់របៀបរៀបរយរបស់សង្គមខ្មែរដែលគេយកគោលការណ៍អស់នេះមកអនុវត្តន៍ដែរ ។

ការសិក្សាលោកនីតិនិងចរិយាសាស្ត្រមិនសំខាន់អ្វី ទីងឲ្យសិស្សទន្ទេញមេរៀនទាំងមាត់នោះទេ សំខាន់បំផុតគឺត្រូវឲ្យគោលការអស់នេះជ្រាបចូលក្នុងចិត្តក្មេង, ឲ្យក្មេងមានទម្លាប់ទីងប្រតិបត្តិគោលការណ៍ជានិច្ចជាកាល ក្នុងជីវភាពរបស់វាហើយការប្រតិបត្តិនេះទៅជាការធម្មតា មិនចាំបាច់ប្រយ័ត្នប្រែងប្រែងអ្វីសោះ ។

តើយើងត្រូវធ្វើដូចម្ដេចក្នុងសាលាយើង ដើម្បីនឹងបានទៅកាន់គោលបំណងទាំងអស់នេះ?

ដើម្បីនឹងឲ្យសិស្សមានទម្លាប់ ប្រព្រឹត្តគោលការណ៍នេះ យើងត្រូវរៀបរយដូចម្ដេចក៏ដោយឲ្យតែបាន ហាត់ប្រតិបត្តិតាំងពីក្នុងសាលាទៅ គឺឲ្យសិស្សរៀនធ្វើការពិសោធន៍ដោយខ្លួនឯង ៗ ការពិសោធន៍នេះកើតឡើងលុះត្រាតែគ្រូយើងរៀបចំឲ្យមានសហករណ៍នៅក្នុងសាលា ៗ នៅពេលបង្រៀនលោកនីតិ ត្រូវបបួលសិស្សឲ្យក្រងលក្ខន្តិកៈនៃសហករណ៍ រៀនបោះឆ្នោតចាត់តាំងមន្ត្រីឲ្យកាន់ការ ហើយឲ្យសិស្សរៀនទទួលខុសត្រូវចំពោះមន្ត្រីទាំងអស់ ៗ ធ្វើរបៀបនេះ សិស្សអាចនឹងយល់ប្រយោជន៍ពិត ៗ នៃគោលការណ៍លោកនីតិទាំងប៉ុន្មាន ៗ ក្នុងពេលដែលបំពេញកិច្ចនីមួយ ៗ នេះ លោកគ្រូគួរឆ្លៀតពន្យល់ពីរបៀបរៀបរយ របស់ស្រុកយើងផងឬក៏យកច្បាប់មែនទែនឲ្យសិស្សពិចារណា ដើម្បីនឹងយកមកអនុវត្តន៍

ក្នុងសហករណ៍ក៏បាន ៗ ដូច្នេះសហករណ៍ជាមធ្យោបាយមួយដើម្បីឲ្យសិស្សរៀនលោកនីតិខ្លួនឯង ដោយប្រតិបត្តិតែម្តងដែលនឹងធ្វើទៅបាន លុះត្រាតែសិស្សយើងស្គាល់គោលបំណងសហករណ៍ខាងក្រោមនេះ ៗ

## សហករណ៍សិស្ស

អ្វីដែលហៅថាសហករណ៍សិស្ស ?

សហករណ៍សិស្សជាសមាគមសិស្សដែលនៅរៀនក្នុងថ្នាក់ឬសាលាជាមួយគ្នា ប្រាថ្នាបំពេញសកម្មភាពផ្សេងៗ ជាមួយគ្នាទាំងអស់ហើយសកម្មភាពនោះត្រូវចូលក្នុងការអប់រំផងដូចជាធ្វើបុណ្យ ឬ លក់ដូរឥវ៉ាន់ដែលសិស្សបានធ្វើ ឬ ដែលបានទៅទិញយកមកពីក្រុងធំៗមក ៗ គោលបំណងមិនមែនចង់រកចំណេញនោះទេគឺចង់ឲ្យសិស្សវាអប់រំខ្លួនឯង ដោយធ្វើការខ្លួនឯង ចង់ឲ្យសិស្សប្រមូលកំឡាំងគ្នា ដើម្បីនឹងបំពេញកិច្ចអ្វីមួយតាមគោលបំណងរបស់វា ចង់ឲ្យសិស្សរៀនគ្រប់គ្រងដោយខ្លួន

ឯង គឺរៀនប្រើលទ្ធិប្រជាធិបតេយ្យ ឲ្យសិស្សរៀនចងសាមគ្គីរវាងគ្នានឹងគ្នា ដើម្បីធ្វើការអ្វីមួយជាប្រយោជន៍ដល់សាលា ឲ្យសិស្សរៀនទទួលការខុសត្រូវពិតៗផង ។

សហករណ៍សិស្ស, បើរៀបរយបានស្រួលបួលទៅជារបៀបបង្រៀនមួយយ៉ាងសក្តិសិទ្ធ អាចឲ្យក្មេងរៀនដោយខ្លួនឯងហើយរៀនធ្វើតែម្តង ។ រៀនរបៀបនេះបេះចាំជាងរៀនទន្ទេញជាច្រើនណាស់ហើយស្របនឹងចិត្តក្មេងផង ។

ដម្បូងបង្អស់, ដើម្បីនឹងបង្កើតសហករណ៍ គ្រូបបួលសិស្សធ្វើលក្ខន្តិកៈ ។ ក្នុងឱកាសនេះយើងពន្យល់ពីរបៀបធ្វើច្បាប់រដ្ឋធម្មនុញ្ញ ។

ក្នុងពេលបោះឆ្នោតរើសអ្នកកាន់ការសហករណ៍ យើងពន្យល់ពីរបៀបបោះឆ្នោត ពីនីតិកាលរបស់តំណាងរាស្ត្រ ៗ សិស្សរៀនពិភាក្សាគ្នា ក្នុងចំណោមរៀនកាន់សៀវភៅគណនេយ្យ ។ សកម្មភាពអស់នេះ បង្កើនការពិសោធន៍របស់ក្មេង

គ្រប់មុខ ។

# កំរូលគន្លិកៈនៃសហករណ៍សិស្ស

## ភាគ ១- កំណើត

មាត្រា ១- ចាប់ពីថ្ងៃ... សិស្សសាលា ប្អូចាក់.- បានបង្កើតសហករណ៍មួយដែលមានទីស្ដីការនៅក្នុងសាលា ។

## ភាគ២- គោលបំណង

មាត្រា ២- នៅក្រោមការត្រួតត្រារបស់លោកគ្រូ សហករណ៍មានគោលបំណងដូចតទៅ៖

-បំពេញសកម្មភាពដើម្បីទំនុកបំរុងសាលា ឬទីងរៀបរយ, រកកម្រៃធ្វើដំណើរ ទីងបង្កើតបណ្ណាល័យ ឬក៏ទីងពង្រីកការទាក់ទងរបស់សាលាទីងញាតិសន្ដាននៃសិស្ស ។

## ភាគ៣- សមាជិក

មាត្រា ៣- ជាសមាជិកនៃសហករណ៍ ៖

១- កម្មិកសមាជិក គឺសិស្សទាំងអស់ក្នុងសាលា ឬក្នុងថ្នាក់ ឬក៏សិស្សចាស់ ៗ,

២- សមាជិកកិត្តិយស គឺជាគ្រូកម្ពុយនៃសិស្ស ឬមិត្តនៃសាលា;

មាត្រា ៤ - សមាជិកណាដែលប្រព្រឹត្តអាកប្បកិរិយានាំឲ្យបំផ្លាញកិត្តិយសនៃសាលាត្រូវបណ្ដេញចេញពីសមាគម ។

## ភាគ ៤- ការត្រួតត្រា

មាត្រា ៥ - សហករណ៍នៅក្រោមការត្រួតត្រានៃអគ្គ-ការដែលមានសមាជិក ៤ នាក់ៈ

នាយក ១ រូប

លេខាធិការ ១ រូប

ហេរញ្ញិក ១ រូប

អនុហេរញ្ញិក ១ រូប

មាត្រា ៦ - សមាជិកទាំងនោះត្រូវតែតាំងដោយវិធី

ដោះឆ្នោតក្នុងបណ្ដាសិស្សទាំងឡាយដែលរៀននៅក្នុងថ្នាក់ឬក្នុងសាលាជាមួយគ្នា ។

## ភាគ ៥ -- ប្រាក់ចំណូល-ចំណាយ-

មាត្រា ៧ – ប្រាក់ចំណូលបានមកពី ៖

– ភាគទាននៃសមាជិក

-- ជំនួយផ្សេងៗ

-- កម្រៃបុណ្យឬសកម្មភាពអ្វីផ្សេងៗ

មាត្រា ៨ – ចំណាយចំពោះទៅ ៖

– ទិញរបស់សម្រាប់ប្រើប្រាស់ក្នុងសាលា ;

– ទិញសៀវភៅសម្រាប់បណ្ណាល័យ ;

– ថ្លៃឈ្នួលយានជំនិះធ្វើដំណើរ ;

– ជំនួយទៅសមាគមណាដែលមានគោលបំណងគួរជួយ ។

មាត្រា ៩ – បញ្ជីនៃសមាគមមាន ៖

១ -- បញ្ជីសម្រាប់សេចក្ដីកត់ហេតុប្រគល់ឲ្យលេខាធិការកាន់ ;

ខ– បញ្ជីហេរញ្ញិកគាន់គី ;

គ– បញ្ជីរាយឈ្មោះសមាជិកនៃសហករណ៍;

ឃ–បញ្ជីគណនេយ្យ;

ង– បញ្ជីរាយឈ្មោះរបស់ ។

មាត្រា ១០ — មហាសន្និបាតត្រូវធ្វើនៅចុងរាល់ ត្រៃមាសដើម្បីទឹងរើសអគ្គការត្រួតត្រាថ្មី ទឹងមើលស្ថានការនៃ សហករណ៍ ។

មាត្រា ១១– បើសហករណ៍រលាយទៅត្រូវបង្វិល របស់ឬប្រាក់ដែលសហករណ៍មានទៅសាលា ទាំងអស់ ។

# ១– ត្រូវប្រយ័ត្នតាមផ្លូវ

១– អ្នកដែលឃើញ ឬដែលឮគេនិយាយពីគ្រោះថ្នាក់តាមថ្នល់ឬទេ ? អ្នកអាចនិយាយប្រាប់មិត្តអ្នកទៅមើល ? តើហេតុអ្វីបានជាមានគ្រោះថ្នាក់នេះ ? បើអ្នកវិញតើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីជៀសវាងគ្រោះថ្នាក់នេះ ?

២– គ្រោះថ្នាក់នោះបណ្ដាលឲ្យខូចខាតអ្វីខ្លះ ?

៣– តាមផ្លូវថ្នល់អ្នកបានឃើញតារាងយ៉ាងណាខ្លះ ? នៅផ្លូវបែក, នៅផ្លូវដែលគេមិនឲ្យទៅ...។ល។ ចូរអ្នកគូរក្នុងសៀវភៅអ្នកមើល ហើយដាក់សេចក្ដីនៅក្រោមនោះផង ។

៤– អ្នកណាដែលបានអានហើយ អាចចាំបទបញ្ញត្តិដែលសរសេរលើស្លាកបិទតាមសសរគោមនៅជិតស្ពាន ឬនៅក្នុងរោងកុនឬទេ ? ហេតុអ្វីបានជាគេប្រកែប្រៀនដូច្នេះ ?

X X
X

ផ្លូវថ្នល់រោងកុនអស់នេះជារបស់សាធារណៈ មនុស្ស

គ្រប់ៗគ្នា ប្រើប្រាស់បាន ៗ ដើម្បីប្រើប្រាស់បានស្រួល ហើយកុំឲ្យមានគ្រោះថ្នាក់ ទើបរាជការបង្កើតច្បាប់សំរាប់ផ្លូវ ដែលយើងត្រូវគោរព ដើម្បីជាប្រយោជន៍ដល់ខ្លួនយើងផង និងជាប្រយោជន៍ដល់មនុស្សទាំងអស់គ្នាផង ៗ នរណាធ្វើល្មើសច្បាប់នេះ ច្រើនតែមានគ្រោះថ្នាក់ដល់ស្លាប់ខ្លួនក៏មានៗ ដូច្នេះយើងត្រូវប្រយ័ត្ន ៗ

១– បើអ្នកដើរតាមផ្លូវ ប្រយ័ត្នកុំដើរកណ្ដាលថ្នល់ ត្រូវឡើងលើចញ្ចើមជានិច្ចជាង ៗ មុននឹងឆ្លងថ្នល់ត្រូវមើលស្ដាំមើលឆ្វេងជាមុនសិន ត្រូវឆ្លងតាមគន្លងដែលគេគូរទុកសំរាប់ឲ្យឆ្លង ៗ កុំប្រទៀងគ្នាតាមផ្លូវឲ្យសោះ ហើយកុំបោលសំបកចេក សំបកក្រូចឬដែកគោលតាមផ្លូវ ក្រែងបណ្ដាលឲ្យមានគ្រោះថ្នាក់ ៗ

២– បើអ្នកជិះកង់ មុននឹងជិះមើល «ខ្សែយាត់» ឲ្យដើរស្រួលសិន បើវេលាយប់មើលភ្លើងឲ្យឆេះស្រួលបួល ៗ ជិះ

តែខាងស្តាំផ្លូវជាដរាប ហើយកុំលឿនពេក ៗ កុំជិះលែងដៃ កុំផ្ទុកឥវ៉ាន់ធ្ងន់ពេកលើកនដាក់របស់ ៗ

=-o-=

# ២- សហករណ៍

១- នៅភូមិអ្នក អ្នកដែលឮគេនិយាយពីសហករណ៍ឬទេ?

២- សួរលោកគ្រូអ្នកមើលតើពដការបង្កើតសហករណ៍ ប្រយោជន៍អ្វី?

៣- បបួលលោកគ្រូអ្នកទៅសុំលក្ខន្តិកៈគេមួយក្បាលមកពិនិត្យមើល ។

X

X X

សហករណ៍ជាសមាគមមួយ ដែលសមាជិកម្នាក់ៗ ប្រកបការអ្វីមួយដោយមិនគិតយកតែកម្រៃជាប្រាក់ផ្ទាល់ខ្លួននោះទេ គឺគិតដល់ការបង្កសាមគ្គីធម៌ដោយចែកចាយប្រយោជន៍ឲ្យបានដល់គ្រប់គ្នាតាមកម្លាំងម្នាក់ៗ ។

សហករណ៍មានច្រើនបែបតែយើងត្រូវស្គាល់តែសហករណ៍ខាងផលិតផលនិងសហករណ៍ខាងប្រើប្រាស់ ។ សហករណ៍ខាងផលិតផលគឺជាសមាគមនៃកម្មករ ដែលជាអ្នកធ្វើរបស់ផង

អ្នកលក់ផង រកដើមទុនខ្លួនឯង ហើយត្រួតត្រាកិច្ចការដោយខ្លួនឯងទៀត ។ ឯចំណែកសហករណ៍ខាងប្រើប្រាស់គឺជាសមាគមមួយចាត់ចែងលក់របស់ប្រើប្រាស់គ្រប់យ៉ាងទៅឲ្យតែសមាជិកខ្លួន សមាជិកនេះផ្តល់ដើមទុនទៅសហករណ៍ ហើយមើលត្រួតត្រាដោយខ្លួនឯងទៀត ។

## ការរៀបរយសហករណ៍

ដើម្បីនឹងបង្កើតសហករណ៍ មុនដំបូងបង្អស់ត្រូវក្រែងលក្ខន្តិកៈ ។ នរណាចូលជាសមាជិកនៃសហករណ៍ត្រូវសន្យាថានឹងគោរពលក្ខន្តិកៈនោះ ។ សមាជិក១រូបៗត្រូវបង់ភាគទានតាមកម្លាំងខ្លួនហើយទទួលបុង់ការខុះពីសហករណ៍, តែបុង់ការនេះថោកណាស់ ។ បើសិនណាជាសហករណ៍មានបំណេញគេចែកទឹកប្រាក់នោះ ទៅសមាជិកគ្រប់រូបតាមកម្លាំងការដែលអ្នកនោះជួនមកសមាគម មិនមែនតាមចំនួនប្រាក់ដើមទុនដែលបង់ទេ ។

ការត្រួតត្រានៃសហករណ៍ប្រគល់ ឲ្យទៅសមាជិកខ្លះ ដែលគេរើសតាំងតាមវិធីបោះឆ្នោតនៅពេលមហាសន្និបាត ។

## ប្រយោជន៍នៃសហករណ៍

ប្រយោជន៍នៃសហករណ៍មានច្រើនតាមបែបសហករណ៍ ៗ អ្នកបង្កើតសមាគមនេះមានគោលបំណងនឹងប្រមូលជនទាំងឡាយដើម្បីនឹងបន្ធូរបន្ថយតម្លៃរបស់ ដោយបំបាត់គំនិតចង់ចំណេញតែម្នាក់ឯង ៗ ដូចជាសហករណ៍ខាងប្រើប្រាស់ គេទិញលក់ខ្លួនឯង ហើយលក់ឲ្យទៅតែសមាជិកឯង ៗ ធ្វើយ៉ាងនេះប្រហែលជាតម្លៃរបស់ចុះថោកបន្តិច ព្រោះគេបានបំបាត់អ្នកជំនួញដែលជាអ្នកគ្រាន់តែនាំទិញពីមួយទៅមួយ ហើយបានកេងកញយកកម្រៃយ៉ាងធំ ៗ ឯចំណែកខាងសហករណ៍ខាងផលិតផលវិញមានគោលបំណងនឹងបំបាត់ «អ្នកមានទុន» ដែលរឹតតែ [illegible] ហើយ [illegible] ៗ

កម្មករផ្ដុំគ្នាជាសហករណ៍ធ្វើស់ក៊ន់ផង ត្រួតត្រាផង លក់យកកម្រៃខ្លួនឯង, យកមកចែកគ្នាឯងមិនបាច់មានអ្នកមេទុនណាមកវែកញែកយកកម្រៃខ្លះបានឡើយ ។

=-oo-=

# ៣- អំពីឃុំនិងភូមិ

១- ភូមិអ្នកឈ្មោះភូមិអ្វី ?

២- ភូមិអ្នកនៅក្រោមអំណាចលោកមេឃុំណា ?

៣- សួរគេមើលតើឃុំរបស់អ្នកទំហំប៉ុន្មាន ? មានប្រជាជនប៉ុន្មាន ?

៤- បបួលលោកគ្រូអ្នកឲ្យគាត់នាំអ្នកគូរផែនទីឃុំអ្នកមើល ហើយគូរកន្លែងភូមិ ឃុំ៖ វត្ត, ថ្នល់, និងផ្លូវដែលមានក្នុងឃុំនោះ ៗ

X

X X

ឃុំគឺភូមិភាគមួយរបស់ដែន ហើយនៅក្រោមការត្រួតត្រារបស់ភ្នាក់ងាររាជការម្នាក់ដែលគេហៅថាលោកមេឃុំ ។ កន្លែងធ្វើការរបស់លោកនៅសាលាឃុំ ធម្មតាច្រើនតែនៅតាមទីប្រជុំជនណាធំជាងគេក្នុងឃុំនោះៗ ដូច្នេះ, ឃុំជាផ្នែកមួយតូចនៃនគរនិមួយ ៗ ផ្នែកនេះមានព្រំប្រទល់ត្រឹមត្រូវ ។ ក្នុងព្រំប្រទល់នេះ លោកមេឃុំអាចចាត់ការរាជការបានទាំងអស់

តាមអនុញ្ញាតច្បាប់ ។ មនុស្សរស់នៅក្នុងព្រំប្រទល់នេះជាជនបំណុះឃុំ,ដីព្រៃ,របស់អ្វីផ្សេងៗក៏នៅក្រោមឱវាទឃុំនោះដែរ។

យើងដឹងថាឃុំនិមួយៗមានឈ្មោះ មានដែនខាន់ដោយព្រំប្រទល់ដាច់ពីឃុំឯទៀត ។ ដូចបុគ្គលម្នាក់ ។ ខុសពីបុគ្គលឯទៀតដូច្នោះដែរ ។ ថែមទាំងមានទ្រព្យ ហើយអាចចាយវាយប្រាក់លក់ដូរ ទូរបស់,ដូចជាបុគ្គលម្នាក់ៗដែរ ។ នេះហើយដែលគេថាឃុំជានីតិបុគ្គលមួយ គឺគេធៀបឃុំទៅនឹងបុគ្គលម្នាក់ដែលច្បាប់សន្មតថាមានជីវិត មានសិទ្ធិតែគ្មានរូបកាយជាមនុស្ស ។ ដើម្បីនឹងបំពេញកិច្ចអ្វីទាំងអស់ ឃុំត្រូវតែមានអ្នកតំណាង ។ លោកមេឃុំជាអ្នកតំណាងនីតិបុគ្គលនេះ ។ របស់អ្វីដែលនៅក្នុងឃុំនោះ ហើយមិនទាន់មានម្ចាស់ដូចជាព្រៃគុម្ពោត, បលណាវត្ត, អចលណាវត្ត ឬរបស់អ្វីជាសាធារណៈដូចជាអណ្ដូងថ្ម,ឬទឹកប្រាក់ ដែលអ្នកស្រុកបានបង់គ្រប់ជំពូកជាទ្រព្យរបស់ឃុំទាំងអស់ ។

X_X_X

# ៤- មេឃុំនឹងសហការី

១ -នៅភូមិអ្នកតើនរណាជាអ្នកផ្សះផ្សារបើមានអ្នកស្រុកឈ្លោះប្រកែកគ្នា ?

២ - បើមានការអ៊ូរនឹងរាជការខុតក្ដមាយអ្នកទៅនិយាយនឹងអ្នកណាខ្លះ? នៅឯណា?

៣- ការណាខ្លះ បានគេទៅប្ដឹងលោកមេឃុំ? រាប់មកមើល ?

៤ - ប្អូនអ្នកទៅសាលាឃុំមើល តើមានអ្នកណាខ្លះធ្វើការនៅទីនោះ?

X

X X

## ការជ្រើសតាំងលោកមេឃុំ

លោកមេឃុំជាអ្នកចាត់ការរាជការផ្សេងៗ នៅក្នុងឃុំរបស់ខ្លួនៗមានជំទប់, ស្មៀន, នឹងមេភូមិធ្វើការតាមលោកផងៗ

ឥឡូវនេះនៅស្រុកយើង គឺលោកចៅហ្វាយស្រុកដែល

ជាអ្នកជ្រើសតាំងមេឃុំក្នុងចំណោមបណ្ដាជនឯទៀត ដែលមានឈ្មោះក្នុងបញ្ជីជាអ្នកត្រឹមត្រូវ ហើយមានសមត្ថភាពគ្រប់គ្រាន់ ។ ជនអស់នេះក៏ត្រូវលោកចៅហ្វាយស្រុករើសដែរ តាមសេចក្ដីយល់ព្រមនៃលោកចៅហ្វាយខេត្ត ។ លោកមេ-ឃុំមានភារៈនឹងរើសសហការីលោកដោយខ្លួនឯងបន្តទៅទៀត តាមសេចក្ដីយល់ព្រមរបស់ចៅហ្វាយស្រុក ។

## ករណីយកិច្ចរបស់មេឃុំ

មេឃុំជាអ្នកដំណាងប្រយោជន៍ឃុំ គឺដំណាងប្រជាជនចំណុះឃុំទៅរបស់ខ្លួន ជាអ្នកចាត់ការរាជការធំប្រាស្រ័យផ្ទាល់នឹងប្រជាជនផង ។ មេឃុំត្រូវការពារប្រយោជន៍នៃប្រ-ជាជនចំណុះឃុំខ្លួន មានភារៈនឹងថែរក្សាទ្រព្យរបស់ឃុំ ដូចជាព្រៃ ថ្នល់ ឬសាលារៀនជាដើម ព្រមទាំងចាត់តាំងវិធានការផ្សេង ៗ ដើម្បីរក្សាសន្តិសុខដល់ប្រជាជន ។ បើលោក

មេឃុំដោះស្រាយការអ្វីៗនដ៏ទំនិទធុន ត្រូវតែនៅចៅហ្វាយស្រុកជាប្រញាប់ ដូចជាមានជម្ងឺឆ្លងអ្វីមួយ ឬហេតុអ្វីមួយដែលនាំបំផ្លាញសេចក្ដីសុខសាន្តត្រាណរបស់ប្រជាជនជាដើម ។ លោកមេឃុំជាអ្នកផ្សះផ្សាជនទាំងឡាយ ដែលឈ្លោះប្រកែកគ្នា ។

ជាអ្នកចាត់ការរដ្ឋាភិបាល លោកមេឃុំត្រូវតាមពន្ធដារសព្វសារពើ ហើយបញ្ជូនប្រាក់នោះទៅឲ្យលោកចៅហ្វាយស្រុក ។ លោកអាចចាប់ឃុំឃាំងតាមបញ្ញត្តិច្បាប់ជនណាមួយដែលល្មើសច្បាប់សម្រាប់រដ្ឋ ។ លោកមេឃុំជាអ្នកកាន់បញ្ជីអត្រានុកូលដ្ឋានសំរាប់ឃុំទៀត ។

—០០—

# ៥- អត្រានុកូលដ្ឋាន

១- គេធ្វើសញ្ញាប័ត្រកំណើតសម្រាប់អ្វី? ពិនិត្យមើលសេចក្ដីស្រង់សញ្ញាប័ត្រកំណើតមួយ តើមានសរសេរអ្វីខ្លះ? មានហត្ថលេខាអ្នកណាខ្លះ?

២- សេចក្ដីស្រង់សញ្ញាប័ត្រកំណើតយកពីណាមក?

៣- អាពាហ៍ពិពាហ៍សញ្ញាប័ត្រប្រយោជន៍អ្វី?

៤- មរណៈភាពប្រយោជន៍អ្វី?

៥- អ្វីដែលគេហៅថាអត្រានុកូលដ្ឋានរបស់ជនម្នាក់ៗ?

X

X V

នៅក្នុងឃុំនិមួយ ៗ មានប្រជាជនជាច្រើនរូប ៗ ដើម្បីដឹងឋានៈនៃជនម្នាក់ ៗ ជាចំណុះឃុំ រាជការតាំងឲ្យមានបញ្ជីសម្រាប់កត់ហេតុផ្សេង ៗ ដែលកើតមានដល់ជនទាំងនោះ គឺកត់ឈ្មោះ អាយុ ទីលំនៅ សែស្រឡាយ... ។ល។ លោកមេឃុំជាអ្នកកាន់បញ្ជីគស់នេះ មានបញ្ជីសំរាប់កត់កំណើត អាពាហ៍

ពិពាហ៍ពិពាហ៍និងមរណៈភាពនៃជនទាំងឡាយៗបញ្ជីអស់នេះ គេហៅថាបញ្ជីអត្រានុកូលដ្ឋាន ។ លោកមេឃុំអាចស្រង់សេចក្ដីដែលកត់នៅក្នុងបញ្ជីនេះ ធ្វើជាសញ្ញាប័ត្រមួយឲ្យទៅសាម៉ីខ្លួនណាដែលត្រូវការប្រើប្រាស់ ដូចជាសញ្ញាប័ត្រកំណើតអ្នកពល់គ្នាជាដើម ។

ដូច្នេះនៅគ្រប់សាលាឃុំមានបញ្ជីកត់កំណើត បញ្ជីកត់អាពាហ៍ពិពាហ៍និងបញ្ជីកត់មរណៈភាព ។ កាលណាមានកូនកើត ឪពុកម្ដាយឬគ្រួពេទ្យឬអ្នកដឹងឮ ត្រូវទៅចុះឈ្មោះកូននោះ ចុះថ្ងៃខែដែលកើត ថែមទាំងឈ្មោះឪពុកម្ដាយក្នុងបញ្ជីកំណើត ។ គឺបញ្ជីនេះហើយដែលលោកមេឃុំស្រង់យកសញ្ញាប័ត្រកំណើត ដើម្បីជាសំអាងថា អ្នកនេះជាកូនអ្នកនោះ ថាអ្នកនេះកើតនៅឃុំនោះ ថាអ្នកនេះមានសញ្ជាតិជាចិន យួន ខ្មែរ ថាអ្នកនេះមានអាយុប៉ុន្មានៗ ។

ចំណែកនៅក្នុងបញ្ជីអាពាហ៍ពិពាហ៍វិញ គេកត់ថ្ងៃខែ

ដែលគេរៀបមង្គលការនឹងឈ្មោះសាម៉ុខួន ៗ មរណៈភាពកត់នៅក្នុងបញ្ជីមរណៈភាព ៗ

បញ្ជីទាំងអស់នេះ មានពីរក្បាលក្នុងមួយមុខ ៗ នៅក្នុងឃុំនិមួយ ៗ ហើយគេផ្លាស់ជាថ្មីតែរាល់ឆ្នាំ ៗ ដល់ពេលដាច់ឆ្នាំគេដំកល់មួយក្បាលនៅសាលាឃុំ មួយក្បាលទៀតគេផ្ញើទៅទុកឯសាលាដំបូង ដើម្បីនឹងប្រយ័ត្នកុំឲ្យបាត់ក្រែងអ្នកសាម៉ុខួនត្រូវការសុំទៅថ្ងៃក្រោយ ៗ

=-oo-=

# ៦- ស្រុកនិងខេត្ត

១-រដ្ឋកម្ពុជាយើងមានខេត្តប៉ុន្មាន? ឈ្មោះអ្វីខ្លះ?

២- នៅទីរួមខេត្តដែលអ្នកនៅមានមន្ទីរចាត់ការរាជការអ្វីខ្លះ? សាលាខេត្ត អគ្គាធិការដ្ឋានខាងបឋមសិក្សា.... អ្វីខ្លះទៀត?

៣-បើអ្នកឆ្លាតថាមកមើល តើខេត្ត, ស្រុកនិងឃុំខុសគ្នាយ៉ាងណាខ្លះ? ហេតុអ្វីបានជាគេចែកដែនកម្ពុជា ជាខេត្តផងជាស្រុកផងនិងជាឃុំផងដូច្នេះ?

* * *

ឃុំច្រើនរួមគ្នាទៅបានជាស្រុកមួយដែលនៅក្រោមការត្រួតត្រានៃមន្ត្រីម្នាក់មានងារជាចៅហ្វាយស្រុក ។ ស្រុកច្រើនរួមគ្នាទៅទៀតបានជាខេត្តដែលនៅក្រោមឱវាទ នៃចៅហ្វាយខេត្ត ។

ដូចជាឃុំដែរ ខេត្តអាចមានទឹកដីទ្រព្យសម្បត្តិផ្សេងៗ ។

ក្នុងការអភិបាលខេត្តនិមួយៗ មានស្វ័យភាពខ្លះដែរ គឺការតួប ល្មមលោកចៅហ្វាយខេត្តអាចកាត់បានតាមមតិរបស់លោក ៗ ដោយយល់ព្រមនឹងសភាដំណាងខេត្ត ៗ នៅក្នុងទីរួមខេត្ត ច្រើនមានមន្ទីរចាត់ការគ្រប់ក្រុម សាធារណៈ ដូចក្រុមសិក្សាធិ-ការជាតិ មានលោកអធិការមួយមើលការខុសត្រូវចំពោះ ក្រសួងលោក ៗ ក្រុមសាធារណៈការមានវិស្វករមួយរូបចាត់ ការតាមមុខក្រសួងគេទៅ ៗ ឯចំណែកស្រុកវិញមិនដូច្នោះ ទេ ស្រុកគ្រាន់តែជាផ្នែកមួយ ដើម្បីនឹងស្រួលធ្វើការផ្ទាល់ ប្រជាជន ៗ ចៅហ្វាយស្រុកគ្រាន់តែជាអ្នកដំណាងចៅហ្វាយ ខេត្តទេនៅទីនោះ ៗ

## ការណីយកិច្ចរបស់ចៅហ្វាយខេត្តនិងចៅហ្វាយស្រុក

លោកចៅហ្វាយខេត្តដោយមានលោកចៅហ្វាយស្រុក នឹងសហការីឯទៀតធ្វើការអមផង ត្រូវចំខ្នះខ្នែងឲ្យសាធារណៈ

ការក្នុងខែត្ររបស់ខ្លួន ដើរទៅឲ្យបានស្រួលបួលដើម្បីជាប្រយោជន៍នៃប្រជាជនទូទៅ ។ វិសេសបំផុតលោកមានភារៈនឹងរក្សាសន្តិសុខក្នុងមណ្ឌលលោកឲ្យបានគង់វង្សយឺនយូរដើម្បីឲ្យប្រជាជនរកស៊ីបានគ្រប់គ្រាន់ ។ ដោយសង្ខេបលោកត្រូវបំពេញកិច្ចរបស់លោកយ៉ាងណាក៏ដោយ ឲ្យតែបង្កើតនូវវឌ្ឍនធម៌ខាងផ្លូវសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ផង ។

លោកជាអ្នកដំណាងរាជការកណ្ដាល លោកមានអំណាចចាត់ការផ្សេងៗដើម្បីឲ្យប្រជាជនគោរពច្បាប់ដោយត្រឹមត្រូវ ។ លោកត្រូវទារពន្ធដារដើម្បីយកទឹកប្រាក់មកប្រើប្រាស់ឲ្យសាធារណៈការដើរបានស្រួល ។

=-oo-=

# ៣- ស្រុកខ្មែរ

១–តើរដ្ឋធម្មនុញ្ញសំរាប់ប្រទេសយើងធ្វើហើយនៅឆ្នាំណា?

២--តើគេបានកែប្រែនៅឆ្នាំណា?

៣--ប្រជាជនដែលនៅក្នុងស្រុកមានរដ្ឋធម្មនុញ្ញ និងប្រជាជនចំណុះស្រុកគ្មានរដ្ឋធម្មនុញ្ញ តើនរណាស្រួលជាង?

៤–សួរលោកគ្រូអ្នកមើល តើបានសេចក្ដីដូចម្ដេចពាក្យថា៖រដ្ឋពជានិយម,សាធារណរដ្ឋ សាធារណរដ្ឋប្រជាមានិតៗ

X

X X

បួករួមឃុំទាំងអស់បានជាស្រុក, ស្រុកទាំងអស់បានជាខេត្រ ខេត្រទាំងអស់បានជាប្រទេស ឬរដ្ឋ ៗ ប្រទេសខ្មែរយើងមានឈ្មោះហៅថាប្រទេសកម្ពុជា ឬរដ្ឋកម្ពុជា ៗ

រដ្ឋកម្ពុជាយើងមានដែនមិនជាធំប៉ុន្មានទេ ធៀបនឹងប្រទេសឯទៀត ៗ ដែនដីនេះ ខ័ណ្ឌពីដែននៃប្រទេសជិតខាងដោយព្រំប្រទល់ ៗ ប្រជាជនរស់នៅក្នុងដែននេះច្រើនតែកាន់

សញ្ជាតិជាខ្មែរ ហើយនៅក្រោមការគ្រប់គ្រងនៃរដ្ឋាភិបាលមួយដែលធ្វើការជាប្រយោជន៍ប្រជាជន ។ សរុបគ្នាទាំងដែនទាំងប្រជាជននឹងទាំងរដ្ឋាភិបាល បានជារដ្ឋកម្ពុជា ។

រដ្ឋកម្ពុជាដូចជាឃុំឬខេត្តដែរ មានទ្រព្យសម្បត្តិអាចនឹងតក្ដីក្ដាំនឹងចង់ទាក់ទងជាមួយរដ្ឋឯទៀត ។ ដូចជាមនុស្សអាចទាក់ទងគ្នានឹងគ្នាដែរ ។ នោះគេសន្មតថារដ្ឋក៏ជានីតិបុគ្គលមួយដែរ ។

រដ្ឋកម្ពុជា ជារដ្ឋរាជានិយមមានរដ្ឋធម្មនុញ្ញ ហើយថែមទាំងកាន់លទ្ធិប្រជាធិបតេយ្យផង គឺថាប្រជាជនខ្មែរមានអំណាចរៀបរយស្រុកដោយខ្លួនឯងៗ ពលរដ្ឋខ្មែរម្នាក់ៗជ្រើសរើសដំណាងដើម្បីនឹងក្រងច្បាប់ជូនសខ្លួន ហើយថែមទាំងមានអំណាចពិនិត្យមើលឲ្យគេអនុវត្តន៍ ច្បាប់នេះឲ្យត្រឹមត្រូវផងទៀត ។

របៀបចាត់តាំងអង្គការរៀបរយស្រុកខ្មែរ គេត្រាទុកក្នុង

ប្រជុំច្បាប់មួយក្បាលមាន១១៧មាត្រាដែលគេហៅថា «រដ្ឋធម្មនុញ្ញ» ។

រដ្ឋធម្មនុញ្ញនេះបានដៅថាត្រូវមាន៖

១—នីតិបញ្ញត្តិ ឬ អំណាចធ្វើច្បាប់ដែលគេប្រគល់ឲ្យទៅរដ្ឋសភា ។ ពេលដែលធ្វើច្បាប់នីមួយៗ រដ្ឋសភាត្រូវស្នើសួរមតិក្រុមប្រឹក្សាព្រះរាជអាណាចក្រនិងសភាជំណាន់ខេត្រផង។

២—នីតិប្រតិបត្តិទទួលភារៈ នឹងអនុវត្តច្បាប់ គេប្រគល់អំណាចនេះឲ្យទៅគណៈរដ្ឋមន្ត្រីដែលធ្វើការក្រោម អធិបតេយ្យភាពនៃនាយករដ្ឋមន្ត្រីនិងព្រះមហាក្សត្រិយ៍ ។

៣—អំណាចតុលាការទទួលភារៈ នឹងជំនុំជំរះជនណាដែលល្មើសច្បាប់ ។ អំណាចនេះគេប្រគល់ទៅឲ្យសាលាជំនុំជំរះក្តី ។

## សង្ខេប

ប្រទេសកម្ពុជាជារដ្ឋរាជានិយមកាន់លទ្ធិប្រជាធិបតេយ្យ

គឺអ្នកដំណាងរាស្ត្រ ដែលប្រជាជនខ្មែរទាំងអស់ មានអាយុពី ២១ឆ្នាំឡើងទៅជ្រើសតាំង ជាអ្នកធ្វើច្បាប់ ។ ច្បាប់នេះ ត្រូវរដ្ឋាភិបាលយកទៅអនុវត្តន៍ នៅក្រោមការត្រួតត្រារបស់ ដំណាងរាស្ត្រនឹងរបស់ប្រជាជនទៀតផង ។ រដ្ឋធម្មនុញ្ញគឺជាប្រជុំច្បាប់ទាំងអស់ថ្លែងពីការចាត់តាំង នឹងរបៀបរៀបរយអង្គការអភិបាលប្រទេស ។ រដ្ឋធម្មនុញ្ញយើងសព្វថ្ងៃនេះធ្វើតាំងពីឆ្នាំ ១៩៤៧មក តែទើបនឹងកែប្រែខ្លះនៅក្នុងឆ្នាំ១៩៥៦នេះ ។

=-○○-=

# ៨-រដ្ឋសភា

១--អ្នកស្គាល់ដំណាងរាស្ត្រមណ្ឌលអ្នកឬទេ? ឈ្មោះអ្វី? តើលោកធ្វើការនៅឯណា ?

២-តើលោកដំណាងរាស្ត្រ ដែលអញ្ជើញមកភូមិអ្នកឬទេ ? តើអ្នកឮគេសួរលោកពីរឿងអ្វីខ្លះ ?

៣--សួរលោកគ្រូអ្នកមើលតើដំណាងរាស្ត្រមានអំណាចស្មើនឹងភ្នាក់ងាររាជការណាខ្លះ ? ម្ដេចបានជាគេថារាស្ត្រធំបើគ្រាន់តែមានដំណាងប៉ុណ្ណោះ?

X

X X

អំណាចនីតិបញ្ញត្តិ ឬអំណាចធ្វើច្បាប់សំរាប់ប្រជាជនខ្មែរនោះ គេប្រគល់ឲ្យទៅរដ្ឋសភា ។ ក្នុងរដ្ឋសភាយើងឥឡូវមានដំណាងរាស្ត្រ៩១រូបធ្វើការ ។ ដំណាងរាស្ត្រ គឺជាអ្នកដែលប្រជាជនយើងទាំងអស់រើសតាំងឡើងដោយវិធីបោះឆ្នោតឲ្យធ្វើការក្នុងរយៈពេល ៤ឆ្នាំ ។ ដល់ផុតរយៈពេលនេះគេ

ដោះឆ្នោតរើសដំណាងម្តងទៀត ។ ពេល ៤ ឆ្នាំនេះគេហៅថានីតិកាលរបស់រដ្ឋសភានីមួយ ៗ ។ មន្ទីររដ្ឋសភាឋិតនៅភ្នំពេញជិតព្រះបរមរាជវាំង ។

ដំណាងរាស្ត្រទទួលអាណត្តិពីប្រជាជន ដើម្បីនឹងក្រងច្បាប់ផ្សេង ៗ សំរាប់គ្រប់គ្រងស្រុកតាមប្រយោជន៍ជាតិ ។ មុននឹងអនុមតិច្បាប់ណាក៏ដោយ ដំណាងរាស្ត្រត្រូវជញ្ជឹងមើលឲ្យមែនទែន តើច្បាប់នោះត្រូវនឹងប្រយោជន៍ជាតិឬទេ ។

ដើម្បីនឹងឲ្យដំណាងរាស្ត្រម្នាក់ ៗ ស្គាល់តែប្រយោជន៍ជាតិ គេរកមធ្យោបាយផ្សេង ៗ ដើម្បីនឹងដោះដំណាងនេះឲ្យរួចចេញពីអំណាចនៃជន ឬសមាគម ឬអង្គការឯទៀតទាំងអស់ ៗ មានច្បាប់ជាច្រើនមាត្រា ចាត់ចែងពីលក្ខណៈរបស់តំណាងរាស្ត្រ ដើម្បីឲ្យអ្នកដំណាងមានសេរីយ៉ាងជាក់ស្តែងគិតទៅតែប្រយោជន៍ជាតិ ។ ដោយហេតុនេះហើយបានជាគេជូនប្រាក់បំណាច់ទៅអ្នកដំណាងរាស្ត្រឲ្យគ្រប់គ្រាន់ កុំឲ្យដំ

ពាក់ព័ន្ធនឹងជនណាឲ្យសោះ ។ គ្មាននរណាអាចនឹងចោទ ឃុំឃាំងលោកឡើយ គេថាអ្នកដំណាងរាស្ត្រមានអភ័យឯក-សិទ្ធិ ។

## សង្ខេប

រដ្ឋសភាកាន់អំណាចនីតិបញ្ញត្តិ គឺជាអ្នកធ្វើច្បាប់សំរាប់ប្រទេស ។ មានដំណាងរាស្ត្រ ៩១ រូប ធ្វើការក្នុងរដ្ឋសភាយើងសព្វថ្ងៃ ។ ដំណាងរាស្ត្រដែលប្រជាជនរើសតាំងធ្វើការជំនួសប្រជាជនខ្មែរទូទៅ នៅក្រោមការត្រួតត្រារបស់ប្រជាជនទៀតផង ។ ប្រជាជនខ្មែរយើងមានសិទ្ធិនឹងទិទៀនដំណាងរាស្ត្រដែលធ្វើខុសនៅពេលសមាជជាតិ ដែលត្រូវមានធ្វើនៅគ្រប់ត្រៃមាស ។ សមាជបើកអំណាចឲ្យប្រជាជនគ្រប់រូបមកបន្ទោសសមាជិកនៃរដ្ឋសភា បុគ្គលិករដ្ឋាភិបាល ដែលធ្វើការមិនស្របនឹងប្រយោជន៍ជាតិ ។ នេះជាការរៀបរយតាមរបៀបប្រជាធិបតេយ្យយ៉ាងប្រសើរទៅហើយ គួរតែ

ប្រជាជនយើងចេះប្រើសិទ្ធិនេះឲ្យស្របតាមសាធារណៈប្រយោជន៍ទើបបានជឿនលឿន ។



# ៩– ក្រុមប្រឹក្សាព្រះរាជអាណាចក្រ

១–សួរលោកគ្រូអ្នកមើលតើមន្ទីរដែលក្រុមប្រឹក្សាព្រះរាជអាណាចក្រធ្វើការនៅឯណា?

២–សមាជិកសភានេះត្រូវអ្នកណាជ្រើសតាំង?

៣–ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានមុខងារអ្វីខ្លះ?

៤–ហេតុម្តេចបានជាត្រូវមានក្រុមប្រឹក្សាព្រះរាជអាណាចក្រផងនៅជិតសភាតំណាងរាស្ត្រ?

៥ –សួរលោកគ្រូអ្នកមើល តើមានអាយុប៉ុន្មានឆ្នាំតិចទើបបានគេឲ្យឈរជាបេក្ខជនខាងតំណាងរាស្ត្រ? អាយុប៉ុន្មានបានគេឲ្យឈរជាបេក្ខជនខាងក្រុមប្រឹក្សាព្រះរាជអាណាចក្រ?

X

X X

នៅជិតសភាតំណាងរាស្ត្រដ្ឋធម្មនុញ្ញតាំងឲ្យមានសភាមួយទៀតដែលគេហៅថាក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រមាន២០រូប។ សមាជិក

ខ្លះត្រូវគេចាត់តាំង ខ្លះទៀតត្រូវគេជ្រើសរើសដោយវិធីបោះឆ្នោតជាអសាកលគឺថា មានតែប្រជាជនភាគខ្លះទេ ដែលមានសិទ្ធិបោះឆ្នោត ។

ព្រះមហាក្សត្រិយ៍ចាត់តាំងសមាជិកបានពីររូប

រដ្ឋសភាចាត់តាំងបាន២រូប

ក្រុមវិជ្ជាជីវៈផ្សេងៗ បោះឆ្នោតរើស៨រូប

ប្រជាជនបោះឆ្នោតរើស៨រូបទៀត ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានភារៈខាងពិនិត្យនឹងឲ្យយោបល់អំពីច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិ ។ ការឲ្យយោបល់នេះត្រូវតែមានជាដាច់ខាតក្នុងកំឡុងយ៉ាងយូរត្រឹមមួយខែ ។ ការឲ្យយោបល់នេះសំខាន់ណាស់ ព្រោះការពិនិត្យច្រើនដងដោយបុគ្គលផ្លែកៗពីគ្នា នាំឲ្យក្លឹ ហើយបើច្បាប់ណាដែលមិនស្របនឹងឆន្ទៈរបស់ជាតិមែនទែននោះ មុខជានឹងត្រូវគេកែប្រែមិនខានឡើយ ។ ដោយហេតុមានភារៈខាងពិនិត្យនឹងឲ្យយោ

បលដូច្នេះបានជាគេកំណត់អាយុរបស់ពេទ្ធជនខាងក្រុមប្រឹក្សា ព្រះរាជអាណាចក្រ ឲ្យច្រើនជាងពេទ្ធជន ខាងដំណាងរាស្ត្រ បន្តិច ៗ ទាល់តែមានអាយុ៤០ឆ្នាំយ៉ាងតិចទើបឈរឈ្មោះជា ពេទ្ធជនក្រុមប្រឹក្សាព្រះរាជណាចក្របានព្រោះគេត្រូវការ យោបល់អ្នកមានពិសោធន៍ច្រើន ។

## សង្ខេប

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជាសភាមួយទៀតការ អមទីងសភាដំណាងរាស្ត្រ ក្នុងកិច្ចក្រងច្បាប់សំរាប់នគរ ។ ក្រុម ប្រឹក្សាព្រះរាជអាណាចក្រ មានភារៈខាងឲ្យយោបល់ក្នុងការ សម្រេចច្បាប់និមួយៗ ។

សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រមាន២០រូប ហើយ ត្រូវមានអាយុយ៉ាងតិច៤០ឆ្នាំទើបឈរឈ្មោះជាពេទ្ធជនឲ្យគេ

បោះឆ្នោតបាន ។ នេះគឺជាការប្រយ័ត្ន មួយដើម្បីនឹងឲ្យច្បាប់នីមួយ ៗ ទទួលការ ពិនិត្យយ៉ាងហ្មត់ចត់របស់រដ្ឋបុរសចាស់ ៗ ដែលមានការពិសោធន៍ដ៏ជ្រៅជ្រះ ។

—៩០០៩—

## ១០– អំណាចនីតិប្រតិបត្តិ

១– នៅក្នុងមនុស្សក្នុងការណាដែលយកបំពានច្បាប់

ផ្សេងៗ មកឲ្យប្រជាជនជិន ?

២– ក្នុងការនេះនៅក្រោមអំណាចក្នុងការណាទៀត?

នៅក្រោមអំណាចរដ្ឋមន្ត្រីណា ?

៣–លោកណាកាន់ដំណែងជានាយករដ្ឋមន្ត្រីនៅពេល

សព្វថ្ងៃនេះ ?

៤– យ៉ាងណាដែលគេហៅថាអំណាចនីតិប្រតិបត្តិ ?

X

X X

គណៈរដ្ឋមន្ត្រីជាអ្នកកាន់អំណាចនីតិប្រតិបត្តិ គឺជាអ្នកអនុវត្តន៍ច្បាប់ ដែលរដ្ឋសភាបានសម្រេចៗ គណៈរដ្ឋមន្ត្រីត្រូវមានសមាជិកយ៉ាងច្រើនត្រឹម១២រូបធ្វើការនៅក្រោមការត្រួតត្រានៃលោកនាយក១រូប ហៅថានាយករដ្ឋមន្ត្រី ។

ព្រះមហាក្សត្រិយ៍ទ្រង់ជ្រើសរើសនាយករដ្ឋមន្ត្រី ។

នាយកនេះរើសរដ្ឋមន្ត្រីឯទៀតខ្លួនឯង ។ តែរដ្ឋមន្ត្រីទាំងអស់ចូលកាន់ដំណែងបាន លុះត្រាតែកាលណាបានទទួលសេចក្តីទុកចិត្តពីរដ្ឋសភាថែមទៀត ។ បើរដ្ឋសភាយល់ព្រម ព្រះករុណាទ្រង់តាំងរដ្ឋមន្ត្រីទាំងអស់ក្នុងដំណែងមុខងារមួយ ៗ តាមដោយព្រះរាជក្រឹត្យ ។

គណរដ្ឋមន្ត្រីប្រជុំគ្នារាល់តែសប្តាហ៍ ដើម្បីចាត់វិធានការណ៍អនុវត្តច្បាប់ ។ លោកនាយករដ្ឋមន្ត្រីសម្រេចការផ្សេង ៗ តាមព្រះរាជក្រឹត្យ ។ ព្រះរាជក្រឹត្យត្រូវទទួលឡាយព្រះហស្តលេខាពីព្រះមហាក្សត្រិយ៍ផង ទើបយកទៅអនុវត្តបាន ។ ការណាតូចល្មម ៗ រដ្ឋមន្ត្រីអាចនឹងសម្រេចបានដែរតាមប្រកាសក្រសួង, តែសេចក្តីសម្រេចរបស់គណរដ្ឋមន្ត្រីទាំងប៉ុន្មាន ត្រូវស្របតាមច្បាប់ដែលរដ្ឋសភាបានធ្វើមកហើយ ។

ក៏ប៉ុន្តែគណៈរដ្ឋមន្ត្រីមានអំណាចព្រាងច្បាប់ដែរ ហើយស្នើទៅឲ្យរដ្ឋសភាអនុមតិ ។ រដ្ឋមន្ត្រីគ្រប់រូបទទួលខុសត្រូវ

រួមគ្នាចំពោះរដ្ឋសភា អំពីកិច្ចនយោបាយទូទៅ ហេតុនេះ ហើយបានជាគេសម្រេចអ្វីនីមួយ ៗ ក្នុងទីប្រជុំ ។ គណរដ្ឋ-មន្ត្រីធ្វើការនៅក្រោមការត្រួតត្រានៃរដ្ឋសភា ។

នៅក្នុងដំណែងរដ្ឋមន្ត្រីត្រូវទទួលខុសត្រូវព្រមគ្នាចំពោះរដ្ឋសភា ។ ដំណាងរាស្ត្រណាក៏ដោយមានអំណាចនឹងសួរដេញដោលរដ្ឋមន្ត្រីណាមួយ ពីអំពើដែលរដ្ឋមន្ត្រីនោះបានប្រ-ព្រឹត្ត។បើកិច្ចរបស់គណរដ្ឋមន្ត្រីមិនពេញចិត្តរដ្ឋសភា រដ្ឋសភាអាចនឹងបោះឆ្នោតដកសេចក្តីទុកចិត្តចេញ ហើយគណរដ្ឋមន្ត្រីត្រូវលាឈប់ទាំងស្រុង ។

មុននឹងធ្វើការអ្វី ដែលត្រូវចាយវាយប្រាក់ ដែលមិនបានគ្រោងទុកជាមុននោះ រដ្ឋមន្ត្រីត្រូវសុំសេចក្តីអនុញ្ញាតពីរដ្ឋសភាទើបធ្វើបាន ។ របៀបនេះ នាំឲ្យរដ្ឋសភាមានអំណាច

លើគណរដ្ឋមន្ត្រីជាច្រើនណាស់ដែរ ព្រោះគណរដ្ឋមន្ត្រីមិន អាចនឹងបំពេញកិច្ចបានទេ បើគ្មានសេចក្តីយល់ព្រមពីដំណាង រាស្ត្រ ។

-ooo-

# ១១- អំណាចតុលាការ

អំណាចតុលាការឬអំណាចកាត់សេចក្ដីតាមយុត្តិធម៌គេប្រគល់ឲ្យទៅសាលាជំនុំជំរះដែលមានចៅក្រមជាច្រើនធ្វើការនៅទីនោះ ។

ចៅក្រម, នៅពេលកាត់ក្ដី, យកច្បាប់តុលាការមកអនុវត្តន៍ ។ ច្បាប់នេះមានត្រាទុកក្នុងច្បាប់ព្រហ្មទណ្ឌនិងក្នុងច្បាប់រដ្ឋប្បវេ-ណីស្រាប់ ។ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការមើលត្រួតត្រាកិច្ចអនុវត្ត ច្បាប់របស់ពួកចៅក្រមឲ្យបានត្រឹមត្រូវជានិច្ច ។

ក្រុមប្រឹក្សានេះមានសមាជិកដូចតទៅ ៖

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអធិបតី

សមាជិក ២ រូប ចាត់តាំងដោយព្រះមហាក្សត្រិយ៍

សមាជិក២រូបទៀត ដែលរដ្ឋសភាជ្រើសតាំង

ចៅក្រមដែលធ្វើការនៅសាលាជំនុំជំរះ ចែកជាពីរពួក៖

ចៅក្រមអ្នកជំនុំជំរះកាត់ក្ដី ១ ពួក និងចៅក្រមមួយពួកទៀត

ចាំតែផ្សំសំណុំរឿងទៅឲ្យ ដូចជាព្រះរាជអាជ្ញាជាដើម ។ ទៅក្រុមការសេចក្ដី ចាំតែសម្រេចថាកូនក្ដីណាខុសឬត្រូវ ឬទទួលទោសប៉ុន្មាន ៗ តាមច្បាប់ ។ ឯចំណែកពួកព្រះរាជ-អាជ្ញា ឬព្រះរាជអាជ្ញារងវិញជាអ្នកដំណាងព្រះមហាក្សត្រិយ៍ ដើម្បីនឹងការពារប្រយោជន៍សង្គមប្រទាំងនឹងប្រយោជន៍បុគ្គលម្នាក់ៗដែលមានលោកមេធាវីជាអ្នកអះអាងការពារដែរ ។ ពួកព្រះរាជអាជ្ញានេះជួនកាលជាអ្នកប្ដឹងក៏បាន ក្នុងរឿងណាដែលមានប្រយោជន៍សង្គមចូលលាយឡំ ។

ក្នុងអំណាចតុលាការនេះព្រះមហាក្សត្រិយ៍ ព្រះអង្គអាចនឹងដោះលែងមនុស្សទោសខ្លះបានដែរ ។ ឯចំណែកខាងរដ្ឋមន្ត្រីវិញ បើមានធ្វើខុស,ត្រូវរដ្ឋសភាប្ដឹងទៅតុលាការជាន់ខ្ពស់ឲ្យជំនុំជំរះ ។ តុលាការនេះមានសមាជិកប្រាំរូបគឺ ៖

គេរើសនៅក្រុមជាន់ខ្ពស់ ២ រូប

វេជ្ជសភារើសសមាជិក ១ រូប

ក្រុមប្រឹក្សាព្រះរាជអាណាចក្ររើស២រូបទៀត ។

-ooo-

# ១២-- ហេតុអ្វីបានជាគេបែកអំណាចជាបី

១- សួរលោកគ្រូអ្នកមើល តើយ៉ាងដូចម្តេច ដែលហៅថា លទ្ធិផ្តាច់ការ ?

២- ចុះបើរាស្ត្រប្រគល់អំណាចទាំងអស់ឲ្យទៅមនុស្សម្នាក់ ១ ឬឲ្យទៅពួកក្រុមមួយ តើខូចអ្វីខ្លះ ?

៣-- ម្តេចក៏ប្រជាជនមិនត្រួតត្រាស្រុកទេសខ្លួនឯង ចាំបោះឆ្នោតឲ្យគេត្រួតត្រាជំនួសខ្លួន បើថាលទ្ធិប្រជាធិបតេយ្យឲ្យរាស្ត្រធំហើយ ?

X X

X

ប្រទេសកម្ពុជាយើងកាន់លទ្ធិប្រជាធិបតេយ្យ ដូចជាប្រទេសគេជាច្រើនទៀតដែរ គឺថាប្រជាជនត្រួតត្រាខ្លួនឯង តែដោយប្រជាជនក្នុងស្រុកនិមួយៗ មានចំនួនច្រើនពេកមកកាន់តំណែងត្រួតត្រាមិនកើត ទើបបបួលគ្នារើសតាំងឲ្យជនណាដែលមានសមត្ថភាពមកធ្វើការនេះជំនួសខ្លួន ៗ ដោយយកគេ

មកធ្វើការជំនួសនេះហើយបានជាត្រូវប្រយ័ត្ន កុំឲ្យអ្នកត្រួតត្រានេះរំលោភលើប្រជាជនវិញ ដើម្បីនឹងសម្លាប់សេរីភាពរបស់រាស្ត្រ ។

ដូច្នេះបានជាគេប្រគល់អំណាចឲ្យអង្គការផ្សេង ៗ ពីគ្នាឲ្យជួយទប់ទល់បង្ខំនឹងគ្នា កុំឲ្យប្រើអំណាចរំលោភលើប្រជាជនទូទៅបាន ។ រដ្ឋសភាទទួលអំណាចគ្រាន់តែក្រងច្បាប់គឺនីតិបញ្ញត្តិ; គណរដ្ឋមន្ត្រីគ្រាន់តែជាអ្នកអនុវត្តច្បាប់ ដែលរដ្ឋសភាសម្រេចរួចហើយ ។ បើសិនណាជាគណរដ្ឋមន្ត្រីចង់រំលោភធ្វើការមិនដិតដល់កិច្ចអនុវត្តនេះ រដ្ឋសភាអាចទម្លាក់គណរដ្ឋមន្ត្រីបាន ។

បើសិនជារដ្ឋសភាធ្វើច្បាប់មិនស្របនឹងប្រយោជន៍ជាតិដោយជាក់ស្ដែង គណរដ្ឋមន្ត្រីអាចស្នើសុំដល់ព្រះមហាក្សត្រិយ៍ហើយនឹងប្រធានក្រុមប្រឹក្សាព្រះរាជណាចក្រ ឲ្យរំលាយរដ្ឋសភាចេញដើម្បីនឹងបោះឆ្នោត, គឺឲ្យប្រជាជនរើស

ដំណាក់ជាបឋមនៃទៀត ។

អំណាចតុលាការ គឺអំណាចកាត់សេចក្តីរកខុសត្រូវរវាងពលរដ្ឋ,គេប្រគល់ឲ្យអង្គការទី៣គឺពួកចៅក្រមដែលទទួលភារៈកាត់សេចក្តីតាមតែច្បាប់ ដែលចងទុកក្នុងច្បាប់ព្រហ្មទណ្ឌនិងច្បាប់រដ្ឋប្បវេណីស្រាប់ ។

=-ooo-=

# ១៣- សភាប្រជារាស្ត្រប្រចាំខេត្តនិងប្រចាំរាជធានី

១– សួរផុតពួកអ្នកមើលតើដំណាងរាស្ត្រប្រចាំខេត្តអ្នកឈ្មោះអ្វីខ្លះ? លោកធ្វើការនៅឯណា ?

២– តើអ្នកណាទឹងបោះឆ្នោតជ្រើសតាំងដំណាងប្រចាំខេត្ត ?

៣– តើអ្នកដំណាងប្រចាំខេត្ត ខុសពីដំណាងរាស្ត្រយ៉ាងណា? ការរបស់សភាដំណាងរាស្ត្រប្រចាំខេត្តធ្វើអ្វីខ្លះ?

X X

X

ពីព្រោះចំនួនប្រជាជនយើងច្រើនពេកគ្រួតគ្រាស្រុកខ្លួនឯងមិនកើតទើបត្រូវរើសតំណាង ឲ្យបំពេញ សាធារណៈកិច្ចជំនួសខ្លួន ។ ប្រជាជនខ្មែរយើងរើសដំណាងឲ្យធ្វើការនៅរដ្ឋសភាមួយពួក នៅសភាប្រចាំខេត្តនិងរាជធានីមួយពួកទៀត ។ សមាជិកនៃសភានេះ ជាអ្នកដំណាងស្រុកនិមួយៗ

ក្នុងខែត្រ ហើយនឹងជាអ្នកដំណាងសង្កាត់និមួយ ៗក្នុងពជជានិៗ សង្កាត់និមួយៗ នឹងស្រុកនិមួយៗ ត្រូវរើសដំណាងខ្លួនមួយរូបៗ ។

រដ្ឋធនុញ្ញបង្កើតឲ្យមានសភាប្រជារាស្ត្រប្រចាំខែត្រនេះមួយទៀត ក្រៅពីរដ្ឋសភាប្រយោជន៍ដើម្បីឲ្យការត្រួតត្រារបស់ប្រជាជនលើរដ្ឋាភិបាលឲ្យបានជិតដិតទៅទៀតៗ សភាប្រជារាស្ត្រប្រចាំខែត្រអាចនឹងមើលសកម្មភាព នៃរដ្ឋបាលទាំងឡាយឲ្យស្របនឹងប្រយោជន៍ទូទៅ ។ ម្យ៉ាងទៀតសភាប្រជារាស្ត្រប្រចាំខែត្រតាំងមន្ទីរធ្វើការនៅទីរួមខែត្រតែម្តង ដើម្បីឲ្យជិតរាស្ត្រស្រួលពឹងពាក់ក្រែងមានការអ្វីផ្សេងៗ ។

ភារៈរបស់សភាប្រជារាស្ត្រប្រចាំខែត្រសំរាប់តែត្រួតត្រាមើលរដ្ឋបាលនឹងរដ្ឋសភាក្នុងកិច្ចការខ្លះ ដូចជា៖

១–រដ្ឋសភាត្រូវសួរយោបល់សភាប្រជារាស្ត្រប្រចាំខែត្រពីការអនុវត្តច្បាប់ថវិកានឹងអំពីការចុះសន្ធិសញ្ញានឹងបរទេស ។

២-សភាប្រជារាស្ត្រប្រចាំខែត្រ មើលការខុសត្រូវក្នុងកិច្ចធ្វើឋវិការខែត្រ,ឃុំនៅចំណុះខ្លួន ។

៣-សភាប្រចាំខែត្រពិនិត្យការចាត់ចែងនៃសាធារណៈការក្នុងតម្បន់របស់ខ្លួន ហើយសមាជិកសភានេះមានអំណាចដេញដោលភ្នាក់ងាររាជការនានា ។ បើសភាប្រជារាស្ត្រប្រចាំខែត្រមិនទុកចិត្តលើភ្នាក់ងាររាជការណាមួយ សភានេះអាចនឹងស្នើទៅក្រុមប្រឹក្សាព្រះរាជអាណាចក្រឲ្យផ្លាស់បាន ។

ដូច្នេះសភាប្រជារាស្ត្រប្រចាំខែត្រ គឺជាសភាដំណាងរាស្ត្រមួយទៀតនៅជិតប្រជាជនជាងរដ្ឋសភា ដើម្បីនឹងឲ្យប្រជាជនស្រួលស្នើពីរឿងអ្វីផ្សេងៗ ។ ដែលធ្វើយ៉ាងនេះនាំឲ្យប្រជាជនរិតតែមានអំណាចលើរដ្ឋាភិបាលបន្តិចទៀត ។

=-oo-=

# ១៤- ការបោះឆ្នោត

១–អ្នកដែលឃើញប្រជាជនបោះឆ្នោតរើសដំណាងទេឬ? តើរើសដំណាងឲ្យធ្វើទៅសភាណា ?

២–សួរឪពុកអ្នកតើគាត់បានទៅបោះនឹងគេឬទេ?

៣–សួរគាត់មើល តើបោះឆ្នោតប្រយោជន៍អ្វីដល់យើង? បើមិនទៅបោះតើខាតប្រយោជន៍អ្វីឬទេ ?

X X

X

ក្នុងស្រុកដែលកាន់លទ្ធិប្រជាធិបតេយ្យ ពលរដ្ឋម្នាក់ ៗ ត្រូវតែគិតដល់ការត្រួតត្រារបស់ប្រទេស ។ ដោយហេតុថា យើងត្រួតត្រាទាំងអស់គ្នាមិនកើត ទើបបានជាយើងបោះឆ្នោត ។ ការបោះឆ្នោតនេះ សំខាន់ណាស់ព្រោះយើងឲ្យគេធ្វើការជំនួសយើង ។ យើងត្រូវពិចារណារើសតែនរណាដែលយើងទុកចិត្ត អាចនឹងធ្វើការឲ្យទាន់ជឿនលឿនបាន ។ បើយើងមិនទៅបោះក៏ខាតប្រយោជន៍ដែរ ព្រោះជួនកាល

ដោយគ្មានសំឡេងយើងមួយ បេក្ខជនផ្ដេសផ្ដាសអាចបាន ជាប់ជាតំណាងរាស្ត្រធ្វើការសាធារណៈឲ្យខូចខាតអស់ក៏មាន ។ ប្រជាជនស្រុកយើងព្រមទាំងខ្លួនយើង នឹងកើតទុក្ខវេទនាក៏មិនដឹង ។

តាមរដ្ឋធម្មនុញ្ញឥឡូវនេះ ប្រជាជនយើងរើសតំណាង ឲ្យធ្វើក្នុងរដ្ឋសភាកំឡុង ៤ ឆ្នាំ រើសតំណាងឲ្យធ្វើនៅសភា ប្រជារាស្ត្រប្រចាំខេត្តកំឡុងពីរឆ្នាំ ។

ដើម្បីនឹងឲ្យប្រជាជន ១ រូបៗអាចជ្រើសរើសរកតំណាង ណាដែលត្រូវចិត្តខ្លួនពិត, ច្បាប់បានរៀបចំរបៀបបោះឆ្នោត ជាស្រេច ។ សំខាន់បំផុត ច្បាប់ចំការពារឲ្យរាស្ត្របោះឆ្នោត ដោយសេរី គឺថាចំកំចាត់នូវការបង្ខិតបង្ខំ ដើម្បីឲ្យបុគ្គល ម្នាក់ៗរើសតែបេក្ខជនណាដែលខ្លួនពេញចិត្តពិតៗ ។ ដូច្នេះ ហើយបានជាច្បាប់បើកឲ្យប្រជាជនគ្រប់រូប ស្ដាប់ការឃោសនាដោយសេរី

- បើកឲ្យឃោសនាដោយសេរី សរសេរដោយសេរី ដើម្បីឲ្យប្រជាជនគាប់ប្រៀបធៀបដឹងថា បេក្ខជនណាល្អ , ណាអាក្រក់ ។

-បើកឲ្យប្រជាជនជំនុំគ្នាដោយសេរី ។

ម្យ៉ាងទៀតតំណាងរាស្ត្រមួយ ១ ត្រូវតែដំណាងប្រជាជនគាត់ច្រើនដោយពិត ។ ហេតុនេះបានជាគេឲ្យបោះឆ្នោតជាសាកលចំពោះ គឺបើកឲ្យប្រជាជនខ្មែរតាំងអស់ពីអាយុ ២១ទៅមានអំណាចបោះឆ្នោតរើសដំណាងរាស្ត្រផ្ទាល់តែម្តងៗ របៀបនេះផ្ទុយនឹងរបៀបបោះឆ្នោតជាសាកលមិនចំពោះ គឺមានប្រជាជនគាត់ខ្លះគ្មានអំណាចបោះឆ្នោតព្រោះខ្លួនក្រ ឬព្រោះខ្លួនជាស្ត្រីៗ ពាក្យថាមិនចំពោះ គឺថាប្រជាជនមិនរើសដំណាងផ្ទាល់តែម្តងទេ ចាប់រើសអ្នកដំណាងមួយជាន់សិន ហើយអ្នកនោះរើសដំណាងតទៅទៀត គេហៅថាបោះឆ្នោតច្រើន

កន្លាក់ក៏បាន ។ ស្រុកខ្មែរយើងប្រើរបៀបបោះឆ្នោតជាសាកលចំពោះដើម្បីរើសតំណាងរាស្ត្រប្រចាំរដ្ឋសភា និងតំណាងរាស្ត្រប្រ-ចាំខេត្ត តែប្រើរបៀបអសាកលចំពោះ ដើម្បីនឹងរើសសមាជិកក្រុមប្រឹក្សា ។

=-oo-=

# ១៥– តើគេបោះឆ្នោតយ៉ាងដូចម្ដេច

ក្នុងមេរៀននេះ លោកគ្រូបបួលសិស្សរៀនបោះឆ្នោតតែម្ដងក៏បាន ៗ បើលោកគ្រូណាបានបង្កើតសហករណ៍នៅក្នុងថ្នាក់ស្រាប់ គ្រូនោះអាចនឹងពន្យល់ការបោះឆ្នោតនៅពេលដែលសិស្សចាត់តាំងអ្នកដំណាងរបស់ខ្លួនទៅ ៗ

១–តើគេរកមធ្យោបាយយ៉ាងណាខ្លះ ដើម្បីឲ្យប្រជាជនអាចរើសរកដំណាងដែលត្រូវចិត្តខ្លួនពិត ៗ ?

២–តើធ្វើម្ដេចឲ្យប្រជាជនស្គាល់ដំរៀបបេក្ខជនគ្រប់រូប ?

៣–តើធ្វើម្ដេចកុំឲ្យអ្នកខ្លះចង់បន្លំបោះពីរឬបីដង ?

៤–ធ្វើម្ដេចកុំឲ្យប្រជាជនបោះដោយខ្លាច ?

X X

X

ច្បាប់សំរាប់រដ្ឋបានចងទុកជាស្រេចរបៀបបោះឆ្នោតដើម្បីឲ្យប្រជាជនអាចរើសអ្នកណាដែលខ្លួនស្រឡាញ់ពិត ៗ បាន ៗ

ដំបូងបង្អស់មុននឹងបោះឆ្នោតគេទុកពេលឲ្យបេក្ខជនគ្រប់រូបដើរឃោសនាដោយសេរី ៗ គេបើកអំណាចឲ្យប្រជាជនទៅស្តាប់តាមចិត្តដើម្បីនឹងថ្លឹងមើលតើបេក្ខជនណាត្រូវចិត្តខ្លួនជាង ៗ ពេលនេះគេហៅថាសម័យបោះឆ្នោត ៗ

ដល់ពេលបោះឆ្នោត ដើម្បីកុំឲ្យបុគ្គលខ្លះបន្លំបោះពីរបីដងបាន ឬកុំឲ្យបុគ្គលដែលគ្មានសិទ្ធិគ្រប់គ្រាន់ នឹងបោះនោះទៅបោះបាន, ច្បាប់តាំងឲ្យភ្នាក់ងារ ខ្លះធ្វើបញ្ជីក្នុងឃុំនិមួយ ៗ ជាស្រេចចុះឈ្មោះគ្រប់ប្រជាជនដែលមានសិទ្ធិបោះឆ្នោត ៗ ក្នុងស្រុកយើងឥឡូវខេមរជនទាំងស្រីប្រុស ចាប់តាំងពីអាយុ ២១ ឆ្នាំទៅមានសិទ្ធិបោះឆ្នោតទាំងអស់ក្រៅពីមនុស្សឆ្កួត នឹងមនុស្សណាដែលតុលាការឲ្យទោស ៗ នរណាដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតគេចេញកាតបោះឆ្នោតឲ្យជននោះមួយសន្លឹក ៗ ដល់ពេលបោះឆ្នោតត្រូវកាន់កាតនេះទៅបោះទើបបាន ៗ រួចគេដកកាតទុកភ្លាមដើម្បីកុំឲ្យបោះបានពីរដង ៗ

ការបោះឆ្នោតធ្វើនៅការិយាល័យ ដែលរាជការបាន សង់នៅគ្រប់តំបន់ ៗ សមាជិកនៃការិយាល័យនោះដែល មានជំណាន់គ្រប់បេក្ខជន មើលការខុសត្រូវកុំឲ្យមានជំពាក់ ជំពិនទៅថ្ងៃក្រោយ ៗ បំពោះប្រជាជនបោះឆ្នោតវិញ គេចាំរៀបចំខាងសម្ភារៈ ដើម្បីការពារឲ្យបោះឆ្នោតដោយ សេរី ដូចគេបង្កើតឲ្យមានបន្ទប់រើសឆ្នោតជាដើម ៗ របៀប នេះគេហៅថាបោះឆ្នោតដោយសំងាត់ ៗ គឺក្នុងបន្ទប់នេះ ហើយដែលជនម្នាក់ ៗ រើសឆ្នោតតាមចិត្តខ្លួនស្រឡាញ់ពិត ៗ ហើយបត់ឆ្នោតនោះយកទៅដាក់ក្នុងហិបមួយ ៗ

ដល់បោះឆ្នោតរួច គេយកឆ្នោតពីហិបនេះទៅរាប់មើលបេក្ខ ជនណាបានសន្លឹកឆ្នោតភាគច្រើនជាងគេ បេក្ខជននោះជាប់ជា អ្នកជំណាន់ ៗ សន្មតថាជាប់ជាជំណាន់រាស្ត្រ តាល់ តែបេក្ខ ជនណាបានសន្លឹកឆ្នោតច្រើនជាងគេជាជាប់ខាត ៗ បេក្ខ- ជនណាបានភាគច្រើនជាជាប់ខាត លុះត្រាតែបេក្ខជននោះ

បានសន្និកវេទ្ធាតច្រើនលើសពីចំនួនពាក់កណ្ដាល នៃចំនួនជន ដែលត្រូវបោះឆ្នោតនៅមណ្ឌលនោះ ដូចជាមានអ្នកបោះឆ្នោតទាំងអស់ចំនួន ៥០ រូប បេក្ខជនណាមួយបានភាគច្រើនដាច់ខាត លុះត្រាតែបានឆ្នោតយ៉ាងតិចបំផុតត្រឹម២៦ បើបានចំនួនក្រោមពីនោះមកគេហៅថាភាគច្រើនធម្មតា ។

០០០

# ១៦- ច្បាប់

១–តើអ្នកដែលបានដឹងថាពជការឃុំ ហាមឃាត់ឬបញ្ជាអ្នកស្រុកឲ្យធ្វើអ្វីឬទេ? សេចក្តីហាមឃាត់ឬបញ្ជាក៏ជាច្បាប់ដែរឬ?

២–អ្នកគិតមើលឲ្យមែនទែន តើការហាមឃាត់ឬបញ្ជានេះប្រយោជន៍អ្វី? ដើម្បីប្រយោជន៍ទូទៅ ឬប្រយោជន៍បុគ្គលម្នាក់ៗ?

៣–សួរលោកគ្រូអ្នកមើល ឬរកក្នុងកាសែតណាមួយ តើច្បាប់អ្វីដែលរដ្ឋសភា ទើបនឹងបានអនុម័ត ក្នុងពេលមុនឆាប់ៗនេះ?

៤–សួរគាត់មើលតើនរណាព្រាងច្បាប់ហ្នឹង? ហើយធ្វើច្បាប់ប្រយោជន៍ជនណាខ្លះ?

X

X X

ច្បាប់គឺសេចក្ដីបញ្ជាចេញពីរដ្ឋាភិបាលមក ហើយដែលត្រូវឲ្យប្រជាជនប្រតិបត្តិតាម ។ ច្បាប់ប្រាប់ឲ្យយើងធ្វើអ្វីមួយ ឬមិនត្រូវធ្វើ ។ យើងបាននិយាយថា ស្រុកកាន់របបប្រជាធិបតេយ្យ រាស្ត្រត្រូវត្រួតត្រាខ្លួនឯង ចុះម្ដេចបានជាច្បាប់បង្ខិតបង្ខំដូច្នេះ? បូរយើងដឹងថាច្បាប់មិនមែនជាការបង្ខិតពីក្រៅទេ គឺទឹកចិត្តរបស់ជនភាគច្រើន ហើយប្រជាជនគ្រប់គ្នាត្រូវគោរពទឹកចិត្តនេះ ដើម្បីជាប្រយោជន៍ទាំងអស់គ្នា ។ ដូច្នេះបានជាគេថាច្បាប់ជាសេចក្ដីសំដែងឆន្ទៈរបស់ប្រជាជាតិ គឺថាច្បាប់ចេញពីចិត្តប្រជាជនទាំងអស់ ព្រោះរដ្ឋសភាដែលជាអ្នកដំណាងយើងបានយល់ព្រមហើយ ។

---

អំណាចធ្វើច្បាប់ប្រគល់ទៅលើដៃរដ្ឋសភា ។ សមា-

ជិកនៃរដ្ឋសភា នឹងរដ្ឋមន្ត្រីគ្រប់រូប អាចព្រាងច្បាប់ឲ្យទៅរដ្ឋសភាសំរេចដោយវិធីបោះឆ្នោត ។

សេចក្តីព្រាងច្បាប់ណាដែលសភាដំណាងរាស្ត្រអនុមតិរួចហើយ គេបញ្ជូនឲ្យទៅក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យនឹងឲ្យយោបល់ ។ ក្រុមប្រឹក្សាត្រូវឲ្យយោបល់ក្នុងកំឡុងមួយខែ បើយោបល់នោះ ស្របគ្នា នឹងយោបល់របស់រដ្ឋសភា ច្បាប់នោះអាចនឹងយកទៅអនុវត្តន៍បាន ។ បើក្រុមប្រឹក្សាសុំឲ្យកែប្រែខ្លះ រដ្ឋសភាយកច្បាប់មកសម្រួលម្តងទៀតហើយ បង្វិលបែកគ្នាពិនិត្យលុះត្រាតែស្របគ្នា ក្នុងកំណត់មួយខែ ។ បើក្រុមប្រឹក្សាបដិសេធសេចក្តីព្រាងចោលស្រឡះរដ្ឋសភាត្រូវបង្អង់អស់រយៈកាលពីរខែក្រោយមក ទើបយកមកពិចារណាទៀតបាន ។ ការបញ្ចេញមតិចំពោះសេចក្តីព្រាងច្បាប់ជាលើកទី ២ ត្រូវធ្វើដោយវិធីបោះឆ្នោតយកតាមភាគច្រើនដាច់ខាត ។

ច្បាប់ណាដែលបានសម្រេចហើយត្រូវយកទៅប្រកាស

ឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។



# ១៧- រដ្ឋបាល

តើនរណាធ្វើឲ្យអ្នកដើរ តើនរណាជួយការពារអ្នកពីអំពើឃោរឃៅនៃចោរព្រៃ? អ្នកណាបង្រៀនអ្នក?

X

X X

គឺពួកវិស្វករធ្វើថ្នល់ គឺពួកទាហាននឹងកងរក្សាខេត្ត គឺគ្រូបង្រៀន ។ អ្នកទាំងអស់នេះហើយ ដែលគេហៅថាភ្នាក់ងារ រាជការឬភ្នាក់ងាររដ្ឋបាល មានការៈនឹងបំពេញកិច្ចការសាធារណៈ សំរាប់ប្រយោជន៍ទូទៅ ។ បុគ្គលិកទាំងអស់ដែលគេហៅជម្មតាថាមន្ត្រីនោះ ធ្វើការក្រោមអំណាចគណៈរដ្ឋមន្ត្រី ។ ដូច្នេះរដ្ឋបាលជាអង្គការមួយដែលសំរាប់ធ្វើការដើម្បីជាប្រយោជន៍ប្រជាជនទូទៅ ហើយនៅក្រោមការត្រួតត្រានៃគណៈរដ្ឋមន្ត្រីធំ ។

រដ្ឋមន្ត្រីនិមួយៗត្រួតត្រាមើលភ្នាក់ងារក្នុងក្រសួងរបស់ខ្លួន ។ រដ្ឋមន្ត្រីសុខាភិបាល ត្រួតត្រាក្រុមសុខាភិបាល ។

រដ្ឋមន្ត្រីសិក្សាធិការ ត្រួតត្រាក្រុមសិក្សាជាតិ ។ ល ។

រដ្ឋមន្ត្រីទីមួយៗនេះលោកធ្វើការឯកត្តំពេញនៅក្នុងក្រសួងលោក ហើយលោកមានសហការីរបស់លោកធ្វើការបន្តគ្នាទៅតាមឋានន្តរស័ក្តិនៅគ្រប់ទីួមខេត្ត, ស្រុក, ឃុំតាមតែត្រូវការៗដូចេះបានជានៅឃុំអ្នក គេឃើញមាន «ប៉ូលិស» មេឃុំ នៅស្រុកមានចៅហ្វាយស្រុក នៅលើទៀតមានចៅហ្វាយខេត្ត ។ ល ។

## សង្ខេប

រាជការឬរដ្ឋបាលជាអង្គការដែលធ្វើការនៅក្រោមអំណាចនៃគណៈរដ្ឋមន្ត្រីហើយសំរាប់ផ្តល់ប្រយោជន៍ឲ្យប្រជាជនទូទៅ ។ រដ្ឋបាលមានចែកជាក្រសួងតាមមុខការដែលត្រូវធ្វើ ។ ក្រសួងពេទ្យ, ក្រសួងសិក្សាធិការ, ក្រសួងសាធារណការ, ក្រសួងហិរញ្ញវត្ថុ ។ ល ។ ក្រសួងទាំងអស់នេះតាំងឡើងដើម្បីទឹងគ្រប់គ្រងស្រុក ឲ្យបានសន្តិសុខឲ្យរៀប

រយ បង្កើនផលិតផលរបស់ជាតិ ផ្លូវគមនាគមន៍-ការសិក្សាជាតិ និងពង្រីកសាមគ្គីក្នុងសង្គមជាតិ ។

ក្រសួងនិមួយ ៗ ថិតនៅក្រោមអំណាចរដ្ឋមន្ត្រីមួយរូប ដែលតាំងការិយាល័យនៅរាជធានី ។ ហើយលោកមានសហការីលោកចាត់ការគ្រប់ទីរួមខែត្រទៀត ។

»-ooo-«

# ១៨– ក្រសួងសិក្សាធិការជាតិ

១--សាលាអ្នកតើអ្នកណាសង់? អ្នកណាថែរក្សា?

២–តើសាលាដែលអ្នករៀនដំបូង នៅកន្លែងណាសិក្សាអ្វី?

៣–ប្ដូរអ្នកពប់ភ្នាក់ងារពេដការខាងសិក្សាធិការមើល? ទៅពីលោកគ្រូយើងទៅមានលោកណាទៀតខ្លះ?

៤– ដល់រៀនផុតពីសាលាបឋមសិក្សាតើអ្នកទៅរៀនសាលាណាទៀត? លោកគ្រូនៅបង្ហាត់នោះគេហៅអ្វី ?

X X
X

ក្រសួងសិក្សាធិការជាតិ មានភារៈផ្ដល់វប្បធម៌ដល់ពលរដ្ឋទាំងអស់មិនថាចាស់ មិនថាក្មេង មិនថាប្រុសឬស្រី ។ រដ្ឋមន្ត្រីសិក្សាធិការជាតិកាន់កាប់ក្រសួងនេះជាមួយនឹងលោកចាងហ្វាងនៃសិក្សាធិការជាតិ នឹងលោកអធិការនាយកនៃ

បឋមសិក្សា ៗ មន្ទីរបោះការរបស់លោកបិតនៅក្នុងខេត្ត ៗ នៅតាមទីរួមខេត្រ លោករដ្ឋមន្ត្រីប្រគល់ការត្រួតត្រាលើសាលាបឋមសិក្សាទៅឲ្យលោកអធិការមួយរូប ៗ

សិក្សាធិការខ្មែរយើងចែកជាបីភូមិ ៖

១–បឋមសិក្សាគឺភូមិសិក្សាដំបូងបង្អស់ ៗ កុមារកុមារីទាំងឡាយរៀនទៅភូមិនេះកំឡុង ៦ ឆ្នាំ ទើបបានត្រូវប្រឡងចេញឡើងទៅភូមិខាងលើទៀត ៗ ការត្រួតត្រាបឋមសិក្សាក្នុង១ខែត្រ ៗ ប្រគល់ឲ្យទៅលោកអធិការបឋមសិក្សាមួយរូប ៗ លោកអធិការទាំងអស់ធ្វើការក្រោមបង្គាប់លោកអធិការនាយកមួយរូបតាំងនៅរាជធានី ៗ

២–មធ្យមសិក្សាគឺភូមិសិក្សាបន្ទាប់មក ៗ កន្លែងដែលសិស្សមធ្យមសិក្សារៀនហៅថាអនុវិទ្យាល័យ ឬវិទ្យាល័យ

បើគ្រឹះស្ថាននេះមានគ្រប់ថ្នាក់នៃមធ្យមសិក្សា ។ លោកគ្រូបង្រៀននៅទីនោះគេហៅថាសាស្ត្រាចារ្យ ។

៣ – ឧត្តមសិក្សាគឺជាសិក្សាជាន់ខ្ពស់បំផុត ។ នៅស្រុកខ្មែរឧត្តមសិក្សាទើបតែនឹងកើតឡើងបន្តិចបន្តួច ។ វិទ្យាស្ថានជាតិខាងនីតិសាស្ត្រ នយោបាយនឹងសេដ្ឋសាស្ត្រសាលាភូមិន្ទរដ្ឋបាល សាលាភូមិន្ទវិជ្ជាពេទ្យ ជាគ្រឹះស្ថាននៃឧត្តម-សិក្សា ។

រដ្ឋមន្ត្រី ក្រសួងសិក្សាធិការជាតិ



# ១៩_ក្រសួងសាធារណការ

១-- មើលផែនទីថ្នល់នៅក្នុងស្រុកយើងមើល តើផែនទីផ្លូវទេះភ្លើង វែងឬខ្លី?

២-- តើក្រសួងណាកាន់កាប់?

៣-- នៅឃុំអ្នក, បើមានគេសង់ស្ពាន សង់ផ្ទះសំរាប់រាជការ ឬសាលារៀន សួរគេមើលតើក្រសួងណាចាត់ចែងការស្ថាបនានេះ? នរណាចេញប្រាក់ចំណាយ?

ស ស

ស

ក្រសួងសាធារណការទទួលភារៈចាត់ចែងការធំៗរបស់រាជការដែលជាប្រយោជន៍របស់សាធារណជន ឬក៏ចាត់ចែងសង់គ្រឹះស្ថានសាធារណៈ ដូចជាសាលា មន្ទីរពេទ្យជាដើមៗ ការសង់និងការថែរក្សាផ្លូវអាគមនាគមន៍ដូចជាស្ពាន ព្រែកជីកថ្នល់, ការសង់មន្ទីរចាត់ការរាជការ, ការគ្រប់គ្រងក្រុមប្រៃសណីយ៍ជាដើម សុទ្ធតែរាប់ចូលក្នុងដំណែងនៃក្រសួងសា-

ធារណៈការទាំងអស់ ។

របស់ទាំងអស់នេះសុទ្ធតែធ្វើសំរាប់ប្រយោជន៍ប្រជាជន ផ្លូវសំរាប់ប្រជាជនដើរ សាលាសំរាប់កូនចៅប្រជាជនរៀន ។ ដូច្នេះ គួរយើងទុករបស់អស់នេះដូចជារបស់យើងផ្ទាល់ ហើយយើងត្រូវជួយថែរក្សាឲ្យបានគង់វង់យូរ កុំចេះតែប្រើដោយខ្ជីខ្ជានោះ ៗ ម្យ៉ាងទៀត គួរយើងជួយចាំមើលភ្នាក់ងាររាជ-ការដែលរៀបចំការអស់នេះ ឲ្យបំពេញកិច្ចខ្លួនដោយត្រឹមត្រូវផង កុំឲ្យវិស្សុករទាំងឡាយចាយវាយប្រាក់ថវិកាជាតិសំរាប់ការស្ថាបនានោះខ្ជះខ្ជាយឥតប្រយោជន៍ ។

ក្រសួងនេះឋិតនៅក្រោមអំណាចលោករដ្ឋមន្ត្រីសាធា-រណការ ដែលលោកតាំងមន្ទីរចាត់ការនៅភ្នំពេញ ។ វិស្សុករជាច្រើនដែលមានវិស្សុករនាយក១រូបជាអ្នកត្រួតត្រា, ជាសហការីរបស់លោករដ្ឋមន្ត្រី ។ នៅគ្រប់ទីរួមខេត្ត គេមានតាំងមន្ទីរសាធារណការប្រចាំខេត្តនីមួយ ៗ ។ កម្មករជួសជុលថ្នល់

ដែលអ្នកធ្លាប់ឃើញនៅតាមផ្លូវ ធ្វើការឲ្យក្រសួងសាធារណការនោះហើយ ។

ក្រសួងសាធារណការ មានគោលបំណងតែមួយ គឺធ្វើការដើម្បីនឹងស្ថាបនាគ្រឿងសម្ភារៈ សំរាប់បង្កើនពាណិជ្ជកម្ម, ឧស្សាហកម្ម នឹងកសិកម្មរបស់ប្រទេសជាតិ ហើយនឹងជួយដំកើងជីវភាពប្រជាជនខ្មែរ ខាងផ្លូវសម្ភារៈក៏ដោយ ខាងផ្លូវសីលធម៌ក៏ដោយ ដែលជាលក្ខណនាំឲ្យអារ្យធម៌ស្គាល់នូវវឌ្ឍនធម៌យ៉ាងឆាប់ ។

ល

ល ល

# ២០-ក្រសួងយុត្តិធម៌

១-នៅភូមិអ្នក បើមានការឈ្លោះប្រកែកគ្នា អ្នកស្រុកទៅប្តឹងអ្នកណា? តើអ្នកការនោះធ្វើអ្វីខ្លះ?

២- អ្នកដែលទៅមើលលោកចាងហ្វាង កាត់សេចក្តីនៅសាលាជំនុំជំរះឬទេ? ឃើញលោកចាងហ្វាងអង្គុយត្រង់ណា? លោកព្រះរាជអាជ្ញានៅត្រង់ណា? មេធាវីនៅត្រង់ណា ឃើញអ្នកណាទៀត? គេស្លៀកពាក់យ៉ាងណា? គេធ្វើអ្វីខ្លះៗ

ស

ស ស

ក្រសួងយុត្តិធម៌ ជាក្រសួងមួយទទួលភារៈគ្រប់គ្រងសន្តិភាពនិងសាមគ្គីរវាងពលរដ្ឋ ។ ទៅក្រុមជាច្រើនធ្វើការក្នុងក្រសួងនេះ ចាំតែផ្សះផ្សាអ្នកស្រុកដែលទាស់ទែងគ្នា ឬចាំធ្វើទោសដល់បុគ្គលណា ដែលរំលោភលើគេឯងទៀតតាមច្បាប់អនុញ្ញាត ។ បើមានរឿងហេតុអ្វីប្រជាជនតែងទៅប្តឹងនៅសាលាជំនុំជំរះផ្សេងៗតាមថ្នាក់នៃរឿងនោះ ។

១–សាលាលហុ ជាសាលាជំនុំជំរះជាន់ទាបជាងគេទាំងអស់ ។ នៅសាលានេះ គេទទួលជំនុំតែការណ៍ណាឬទោសណាស្រាល ៗ ។ ច្រើនតែលោកមេឃុំ លោកកាន់ដំណែងជាចៅក្រមសាលាលហុ ហើយការៈរបស់លោកគ្រាន់តែផ្សះផ្សារឲ្យកូនក្តីជានឹងគ្នា ។ បើគេនៅតវ៉ាទៀត ចៅក្រមសាលាលហុអាចនឹងសម្រេចខ្លួនលោកបាន ចំពោះរឿងណាដែលជំពាក់រាក់រៃ កុំឲ្យលើសពី ១០០ រៀល ឬដាក់ទោសឲ្យជាប់ឃុំឃាំងបន្តិចបន្តួច ។

២-- សាលាដំបូង-- បើទោស ឬការណ៍ណាហួសពីសមត្ថភាពនៃសាលាលហុ គេបញ្ជូនទៅសាលាដំបូង ។ ចៅក្រមកាន់ដំណែងធំជាងគេនៅទីនោះ មានងារជាចៅហ្វាង ។ សាលាដំបូងមាននៅគ្រប់ទីរួមខេត្ត នៅភ្នំពេញគេហៅថាសាលាលុកឃុន ។

៣–សាលាឧទ្ធរណ៍- បើសិនណាជាកូនក្តីណាមួយ

មិនសុខចិត្តតាមសេចក្ដីសម្រេចរបស់ចៅក្រមសាលាដំបូង ពីរឿងអ្វីនិមួយៗ គេអាចប្ដឹងទៅសាលាឧទ្ធរណ៍ទៀតបាន ។ សាលានេះគេនឹងពិនិត្យការណ៍សាជាថ្មីឲ្យម្ដងទៀត ។ សេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ជួនកាលក៏ខុសអំពីសេចក្ដីសម្រេចរបស់សាលាដំបូង ។

៤—សាលាឧក្រិដ្ឋ—: សាលានេះសម្រាប់ជំនុំជំរះតែរឿងណាដែលអាចបណ្ដាលឲ្យជាប់ទោសឧក្រិដ្ឋ ដូចជាប្លន់កាប់សម្លាប់គេជាដើម ។ ត្រូវយល់ដឹងថាសាលាឧក្រិដ្ឋមិនទទួលពិនិត្យការណ៍ណាដែលកើតមកពីប្រាក់កាសឬហេតុឯទៀតទេ ។ នៅសាលានេះខុសពីសាលាឯទៀត ការកាត់សេចក្ដីគេប្រគល់ឲ្យទៅគណៈមួយដែលមានសមាជិកពីរពួក ៖ ចៅក្រមមួយពួកនឹងតំណាងប្រជាជន ដែលគេចាត់តាំងមួយពួក ។

### ហេតុអ្វីបានជាមានសាលាជំនុំជំរះពីរជាន់?

សាលាកាត់សេចក្ដីមានពីរជាន់ជានិច្ច គឺថាបើគូក្ដីមិន

សុខចិត្តនឹងសេចក្ដីសម្រេចរបស់សាលាណាមួយ មានអំណាចនឹងសុំតវ៉ាឲ្យសាលាមួយជាន់ខាងលើពិនិត្យម្ដងទៀត ៗ ដូចជាសាលាដំបូងបានពិនិត្យរឿងមួយ ហើយបានសម្រេចតាមចៅក្រមសាលានេះយល់ បើគូក្ដីមិនសុខចិត្តសុំឡើងទៅឲ្យសាលាឧទ្ធរណ៍ជំនុំជំរះម្ដងទៀតក៏បាន ៗ គេតាំងឲ្យមានសាលាជំនុំជំរះជាពីរជាន់ដូច្នេះ ព្រោះគេចង់ជៀសវាងការភាន់ច្រឡំរបស់ចៅក្រមក្នុងកិច្ចអនុវត្តន៍ច្បាប់ ៗ ក្រែងចៅក្រមសាលាដំបូងពិនិត្យមិនអស់សេចក្ដីទើបគេបើកឲ្យគូក្ដីមានអំណាចនឹងបញ្ជូនការណ៍ទៅឲ្យសាលាឧទ្ធរណ៍ពិនិត្យទៀត ៗ

យ

យ យ

# ២១– សាលាវិនិច្ឆ័យ

១– សាលាជំនុំជំរះខែ្មរមានប៉ុន្មានជាន់ ? សាលាអ្វីខ្លះ ? ហេតុអ្វីបានជាគេឲ្យមានសាលាជំនុំជំរះពីរជាន់ដូច្នេះ ?

២– តើអ្នកដែលឮគេនិយាយឈ្មោះសាលាវិនិច្ឆ័យឬទេ ? តើសាលានោះនៅឯណា ?

៣– បើកមើលក្នុងវចនានុក្រម តើពាក្យនេះមានន័យថាដូចម្ដេច ? តើសាលានេះមានការៈយ៉ាងណា? កាលណាបានក្ដីឡើងសាលានេះ ?

V V

V

សាលាវិនិច្ឆ័យជាសាលាជំនុំជំរះជាន់ខ្ពស់បំផុតក្នុងស្រុកយើង ។ សាលានេះឋិតនៅភ្នំពេញ ។ តែយើងត្រូវដឹងថាសាលានេះ មិនមែនជាសាលាកាត់សេចក្ដីជាន់ទី ៣ ទេ ។ ពិតហើយ បើជាគូក្ដីណាមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់សាលាដំបូង ត្រូវឡើងសាលាឧទ្ធរណ៍ បើ

មិនសុខចិត្តសាលាឧទ្ធរណ៍ឡើងសាលាវិនិច្ឆ័យ ៗ តែសាលាវិនិច្ឆ័យមិនពិនិត្យរឿងនេះម្តងទៀត ដូចជាសាលាឧទ្ធរណ៍ទេ គឺថាគេមិនបើកកាយហេតុការណ៍ ដែលមានឡើងរវាងគូក្តីទេ គេគ្រាន់តែពិនិត្យមើល តើចៅក្រមមុន ៗ អនុវត្តច្បាប់ត្រឹមត្រូវហើយឬនៅ តើចៅក្រមមុនយល់ច្បាប់សម្រាប់រដ្ឋ់បានជាក់ច្បាស់ហើយឬនៅ ៗ ហេតុនេះហើយបានជាគេថា សាលាវិនិច្ឆ័យគេពិនិត្យតែសេចក្តីសម្រេចទេ មិនពិនិត្យរឿងម្តងទៀតទេ ៗ

បើសាលាវិនិច្ឆ័យពិនិត្យទៅឃើញថា សេចក្តីសម្រេចរបស់ចៅក្រមមុនមិនស្របនឹងច្បាប់ សាលានេះក៏បដិសេធចោល ហើយមិនជំនុំរឿងនេះខ្លួនឯងទេ បញ្ជូនទៅឲ្យសាលាឧទ្ធរណ៍ណាមួយកាត់ម្តងទៀត ៗ បើសាលាឧទ្ធរណ៍នេះនៅតែសម្រេចដូចមុន សាលាវិនិច្ឆ័យនឹងសម្រេចខ្លួនឯង ៗ

ដូច្នេះសាលាវិនិច្ឆ័យជាសាលាធំបំផុតក្នុងព្រះរាជអាណា

ចក្រកម្ពុជា ។ ចៅក្រមដែលបានចូលធ្វើការនៅទីនោះសុទ្ធតែចៅក្រមចាស់ៗ មានការពិសោធន៍ច្រើន អាចនឹងមើលខុសត្រូវលើសេចក្ដីសម្រេចចៅក្រមឯទៀតបាន ហើយអាចនឹងឲ្យសាលាជំនុំជំរះឯទៀតៗ អនុវត្តច្បាប់រដ្ឋប្បវេណីបានត្រឹមត្រូវ ។

V

# ២២–ក្រសួងការពារប្រទេស

១-- អ្នកដែលឃើញក្រុម «ប៉ូលិស» នៅភូមិអ្នកឬទេ ? នៅមានការអ្វី?

២-- ភ្នាក់ងារណាខ្លះដែលគេតម្រូវឲ្យមើលថែរក្សាសន្តិសុខនិងរៀបចំកិច្ចអនុវត្តច្បាប់នៅក្នុងឃុំ ឬក្នុងទីក្រុងអ្នក ?

៣--ទាហានដែលនៅស្រុកអ្នកឬទេ? នៅមានការអ្វី?

V V

V

ដើម្បីអនុវត្តច្បាប់ឲ្យបានហ្មត់ចត់ និងថែរក្សាសន្តិសុខដល់ប្រជាជនទូទៅ រដ្ឋាភិបាលត្រូវមានកម្លាំងជាគ្រឿងបង្ខំជនណាដែលរឹងទទឹង ៗ កម្លាំងនេះមានឡើងដោយសារកម្លាំងកងទ័ពមានក្រុមនគរបាលជាតិ មានក្រុមការពារលើផ្ទៃប្រទេស និងក្រុមការពារប្រទេស ។ ក្រុមអស់នេះសុទ្ធតែប្រកបដោយគ្រឿងសាស្ត្រាវុធ តែត្រូវប្រើដើម្បីការពារច្បាប់ និងការពារប្រយោជន៍ទូទៅ ប្រឆាំងនឹងបុគ្គលណាឃោរឃៅចង់ល្មើស

ច្បាប់ ឬបង្ខំរំលោភលើសិទ្ធិរបស់អ្នកឯទៀត ។ ដូច្នោះ យើងត្រូវដឹងថាក្រុមនគរបាលក្តី ក្រុមការពារលើផ្ទៃប្រទេសក្តី សំរាប់តែបំផ្លាញការរំលោភ មិនមែនជាអ្នកប្រើកម្លាំងសំរាប់រំលោភប្រជាជនទេ ។

## ក្រុមការពារលើផ្ទៃប្រទេស

ក្រុមនេះដែលគេច្រើនហៅថាកងរក្សាខេត្ត មានការៈខាងការគ្រប់គ្រងសន្តិសុខឲ្យមាននៅគ្រប់ខេត្ត គឺនៅស្រុកស្រែចំការទាំងអស់ ដោយផ្តន្ទាទោសដល់ជនឃោរឃៅ, ដោយជួយសង្គ្រោះដល់ជនណាមានអាសន្នកិតភ័យ ។ ការប្រើប្រាស់ផ្លូវគមនាគមន៍តាមស្រុកស្រែ ក៏នៅក្រោមអំណាចក្រុមនេះដែរ ។

## ក្រុមព្រះនគរបាលជាតិ

ក្រុមព្រះនគរបាលជាតិមានការៈ ប្រហែលគ្នានឹងការៈកងរក្សាខេត្តដែរ តែក្រុមព្រះនគរបាលជាតិស៊ើបរកអ្នកណា

ដែលចង់បំផ្លាញប្រយោជន៍ជាតិ ហើយនឹងមើលការខុសត្រូវនៅក្នុងទីក្រុង ។ ភ្នាក់ងារដែលអ្នកឃើញចាត់ការតាមផ្លូវនេះ ជាភ្នាក់ងារក្រុមព្រះនគរបាលក្រុងហើយ ។

នៅភ្នំពេញមានក្រុមព្រះនគរបាលក្រុងជាច្រើនសង្កាត់ ធ្វើការក្រោមការត្រួតត្រារបស់លោកស្នងការនាយកមួយរូប ។

## ក្រសួងការពារប្រទេស

ក្រសួងនេះការពារប្រទេសប្រឆាំងនឹងសត្រូវខាងក្រៅ ។ ក្រសួងការពារប្រទេស ត្រួតត្រាលើកងទ័ពស្រុកខ្មែរទាំងអស់ ដែលគេហៅកម្លាំងកងខេមរៈភូមិន្ទ ។ នៅពេលចម្បាំងកាំងផល កងទ័ពនេះហើយ ដែលកប់រងការពារព្រំប្រទល់កុំឲ្យកងទ័ពបរទេសចូលលុកលុយបាន ។

## សង្ខេប

ក្រុមការពារលើផ្ទៃប្រទេសនឹងព្រះនគរបាល មាន ការៈនឹងថែរក្សាសន្តិសុខដល់ប្រជាជន ហើយនឹងអនុវត្ត

ច្បាប់ដែលរដ្ឋសភាអនុមតឲ្យបានត្រឹមត្រូវ ៗ ក្រុមនេះត្រូវជួយជនណាដែលមានគ្រោះថ្នាក់ ហើយចាប់ចងជនណាដែលចង់រំលោភលើច្បាប់ ៗ ឯចំណែកខាងក្រសួងការពារប្រទេសវិញ ត្រូវរ៉ាប់រងថែរក្សាព្រំប្រទល់ដែនខ្មែរឲ្យបានគង់វង់ ៗ

=-oo-=

# ២៣-ច្បាប់ព្រហ្មទណ្ឌនិងច្បាប់រដ្ឋប្បវេណី

១-សួរលោកគ្រូអ្នកមើល ដើម្បីនឹងធ្វើជាចៅក្រមបាន គេត្រូវតែចេះអ្វីខ្លះ ?

២-តើរៀនច្បាប់នៅឯណា?

៣ – តើចៅក្រមកំណត់ទោសដល់អ្នកប្រព្រឹត្តខុសតាមអ្វី ?

X X

X

ចូលយើងដឹងថា ចៅក្រមទាំងឡាយកាត់សេចក្ដីតាមតែច្បាប់ដែលគេក្រងទុកជាស្រេច ។ ចៅក្រមគ្រាន់តែកកាយរកពិនិត្យហេតុការណ៍ដែលគេប្ដឹងមក ឲ្យបានជាក់ច្បាស់ហើយទាញយកច្បាប់ណាមួយមកអនុវត្តន៍តាមការយល់ទៅៗ ដូច្នេះច្បាប់ជាគោលធំរបស់ចៅក្រម ចៅក្រមមិនចេះតែសម្រេចតាមតែចិត្តរបស់ខ្លួននោះទេ ។

ច្បាប់គេបង្កើតទុកជាស្រេច ច្បាប់ព្រហ្មទណ្ឌសំរាប់ប្រើ

ប្រាសចំពោះអធិករណ៍ណា ទាក់ទងដល់សន្តិសុខនឹងប្រយោជន៍សាធារណៈ ហើយតុលាការត្រូវដាក់ទោសជាឃុំឃាំងដល់ជនល្មើស ។ ការសម្លាប់គេលួចប្លន់គេ ចូលក្នុងអំណាចច្បាប់ព្រហ្មទណ្ឌ ។ ឯចំណែកច្បាប់រដ្ឋប្បវេណីវិញ សំរាប់ប្រើប្រាសចំពោះការវិវាទរវាងប្រយោជន៍ឯកជន ទៅក្រុមគ្រាន់តែសម្រេចឲ្យសងប្រយោជន៍គ្នា ទៅវិញទៅមកដូចជារឿងជំពាក់ជាក់វិនប្រាក់កាសជាដើម ។

ហេតុដែលមានច្បាប់ពីរបែបនេះនាំឲ្យមានសាលាជំនុំជំរះពីរបែបដែរ ។ សាលាលហុសាលាដំបូង សាលាឧទ្ធរណ៍ សម្រាប់ពិនិត្យការវិវាទរវាងប្រយោជន៍ឯកជនគឺប្រើច្បាប់រដ្ឋប្បវេណី ។ ចំណែកខាងការវិវាទអាចទាក់ទងដល់ប្រយោជន៍ទូទៅត្រូវចូលសាលាលហុ សាលាដំបូងដែរ បើរឿងតូចតាច តែដល់ទោសឧក្រិដ្ឋត្រូវចូលទៅសាលាឧក្រិដ្ឋ ។ ខាងច្បាប់រដ្ឋប្បវេណី គឺអ្នកទទួលរងគ្រោះនោះឯងជាអ្នកដើមចោទ ។

បើខានច្បាប់ព្រហ្មទណ្ឌវិញ ព្រះរាជអាជ្ញាដែលដំណាង ប្រយោជន៍ទូទៅជាអ្នកដើមចោទវិញ ហើយជាគូក្តីម្ខាងផង ។

ចៅក្រមជាអ្នកចេះច្បាប់ហើយយកច្បាប់នេះទុកជាគោលជានិច្ចក្នុងការកាត់សេចក្តីនិមួយៗ ចៅក្រមមិនត្រូវរំលងច្បាប់ចេះតែថាតាមចិត្តខ្លួននោះទេ ប្រជាជនខ្មែរយើងគ្រប់រូបត្រូវខំខ្នះខ្នែងកុំឲ្យចៅក្រមរំលងច្បាប់បាន ទើបមានសេចក្តីយុត្តិធម៌នៅក្នុងស្រុកយើង ។

=·oo·=

# ២៤–ថវិកាជាតិ

១–តើរដ្ឋបាលត្រូវចាយវាយប្រាក់ឬទេ?

២–តើអ្នកណានឹងគិតគូរចាយវាយប្រាក់រាជការ?

៣–តើគេចាយវាយចំពោះអ្វីខ្លះ?

៤–តើរដ្ឋាភិបាលបានប្រាក់ពីណាខ្លះ?

Z Z
Z

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ–· យើងបានដឹងថារដ្ឋាភិបាល ត្រូវការចាយប្រាក់ដើម្បីកសាងស្រុក ដូចធ្វើថ្នល់សំរាប់ប្រជាជន ទិញអាវុធសំរាប់ការពារប្រទេស ។ល។

ការរកប្រាក់, ការចាយវាយអស់នេះ ជាបន្ទុករបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នឹងភ្នាក់ងារក្រសួងលោកជាច្រើនទៀត ។

ថវិកាជាតិ–. ក្នុងមួយឆ្នាំ ៗ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គ្រោងចំនួនទឹកប្រាក់ ដែលត្រូវចាយចំពោះមុខការផ្សេង ៗ

ហើយនឹងចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋាភិបាល ។ ការគ្រោងចំនួននេះ គេយកទៅឲ្យរដ្ឋសភាអនុមត ។ កិច្ចដែលសម្រេចចំនួនប្រាក់ចំណាយ នឹងប្រាក់ចំណូលនេះហៅថា «ថវិកាជាតិ» ។ បើនិយាយឲ្យច្បាស់ទៅ គឺតារាងប្រាក់ចំណាយ ប្រាក់ចំណូលដែលរដ្ឋសភាយល់ព្រមនេះហៅថា ថវិកាជាតិ ។

ប្រាក់ចំណាយ – រាជការក្រសួងនីមួយ ៗ ត្រូវការចាយប្រាក់ជាច្រើន ដើម្បីនឹងរៀបចំដំណើរសាធារណការឲ្យបានស្រួល ដើម្បីនឹងស្ថាបនាគរឲ្យថ្កុំថ្កើងដូចជាធ្វើថ្នល់ ធ្វើមន្ទីរពេទ្យ ធ្វើរោងចក្រ ។ល។ ការចំណាយអស់នេះសុទ្ធតែធ្វើនៅក្រោមការត្រួតត្រារបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នឹងតាមរបៀបគណនេយ្យយ៉ាងត្រឹមត្រូវ ពុំនោះយនឹងឲ្យនរណាបន្ថំបាន ។

ប្រាក់ចំណូល– រដ្ឋាភិបាលចំណាយប្រាក់ដើម្បី

ផ្តល់ប្រយោជន៍ឲ្យសាធារណជន ដូច្នេះពលរដ្ឋយើងគ្រប់រូបត្រូវតែទទួលចេញប្រាក់ចំណាយនេះម្នាក់បន្តិច ៗ ។ ប្រាក់ដែលកផការធារៈពីប្រជាជនពលរូបនេះ ហើយដែលគេហៅថា «ពន្ធ» ។ ដូច្នេះយើងបង់ពន្ធដើម្បីនឹងឲ្យពផការចាត់ការសំរាប់ប្រយោជន៍រួម មិនមែនសំរាប់បុគ្គលខ្លះទេ ។

ពន្ធមានពីរយ៉ាង គឺពន្ធចំពោះនឹងពន្ធមិនចំពោះ ។ ពន្ធចំពោះ គឺពន្ធដែលបុគ្គលម្នាក់ ៗ ត្រូវបង់ជានិច្ចកាលដោយគេទុកបាយដៀសមិនរួច ដូចជាពន្ធខ្លួនជាដើម ។ ពន្ធនេះជាពន្ធផ្ទាល់ខ្លួនយើង ជាប់នឹងយើងជានិច្ច ។ ចំណែកពន្ធមិនចំពោះវិញ គឺពន្ធដែលយើងត្រូវបង់លុះត្រាតែយើងបំពេញកិច្ចអ្វីមួយ ដែលគេសន្មតថាត្រូវចេញថ្លៃឲ្យពផការដូចជាការលក់ដូរទិញផ្ទះជាដើម កាលណាយើងលក់ដូរទិញរបស់ទើបយើងបង់ពន្ធ ។ បើយើងមិនលក់ទេ គ្មាន

នរណាមកទារពន្ធយើងឡើយ ។ ពន្ធនេះមិនមែនផ្ទាល់ខ្លួនទេ ជាពន្ធផ្ទាប់ទៅនឹងកិច្ចអ្វីមួយ ។ យើងអាចជៀសវាងរួចបានដោយកុំប្រព្រឹត្តកិច្ចនោះឲ្យសោះ ។ ហេតុនេះបានជាគេថាពន្ធមិនបំពោះ ។

X X
X

# ២៥– សិទ្ធិរបស់ប្រជាជន

១–ដូចម្ដេចដែលគេហៅថាមនុស្សខ្ញុំគេ? ដូចម្ដេចដែលគេហៅថាមនុស្សអ្នកជា ?

២–ឋានៈរបស់ជនខ្ញុំគេស្រួលឬទេ ?

៣–ជនខ្ញុំគេ ឬជនអ្នកជាដែលមានសេរីភាព?

៤–បើលោកគ្រូអ្នកឲ្យមិត្តអ្នកខ្លះអង្គុយតុល្អ ខ្លះទៀតឲ្យអង្គុយតុអាក្រក់ អ្នកសុខចិត្តឬទេ? អ្វីដែលគេហៅថាសម-ភាពនោះ?

X X

X

សេរីភាព ប្រជាជនខ្មែរយើងមានសេរីភាពបរិបូណ៌ មានសេរីភាពខាងជំនឿ ក្នុងការនិយាយ, ការសរសេរ, ការបោះពុម្ពផ្សាយ និងការអ្វីផ្សេងៗទៀត គឺថាពលរដ្ឋម្នាក់ៗ អាចធ្វើអ្វីបានតាមចិត្ត កុំឲ្យតែប៉ះពាល់ឬឲ្យខូចសិទ្ធិអ្នកដទៃ

**សមភាព**– ប្រជាជនយើងមានសិទ្ធិស្មើគ្នាទាំង

អស់ ៗ បើជនណាមួយអាចធ្វើអ្វីបាន ជនឯទៀតក៏អាចធ្វើបានដូចគ្នា មិនថាជននោះមានឋានៈយ៉ាងណាៗឡើយ ។ នេះហើយដែលគេហៅថាសមភាព ។

គេធានាអះអាងសេរីភាព នឹងសមភាពរបស់ប្រជាជនដោយសារច្បាប់ ។ អ្នកណាធ្វើអ្វីក៏ដោយសុទ្ធតែតាមច្បាប់ទាំងអស់ ។ តែច្បាប់មិនអនុញ្ញាតឲ្យធ្វើ គ្មាននរណានឹងធ្វើបានឡើយ ។ អ្នករាជការចាប់ឃុំឃាំងដាក់ទោសជនល្មើសបានលុះត្រាតែមានច្បាប់អនុញ្ញាតឲ្យធ្វើ ។ ច្បាប់នេះហើយដែលជាគ្រឿងសំរាប់រក្សាសេរីភាព របស់បុគ្គលម្នាក់ៗកុំឲ្យអ្នកណារំលោភលើអ្នកណាបាន ។ ហើយច្បាប់នេះជាសេចក្តីសំដែងទឹកចិត្តរបស់ប្រជាជនទាំងអស់ ។ ពលរដ្ឋគ្រប់រូបមានអំណាចនឹងជួយគ្រងច្បាប់នេះដោយខ្លួនឯង ។

សិទ្ធិប្រជាជនមានច្រើន តែសិទ្ធិសំខាន់ ៗ គឺសិទ្ធិរួបរួម គ្នាជាសមាគមដើម្បីនឹងយកកម្លាំងធ្វើកិច្ចអ្វីមួយ ។

ខេមរជនទាំងពួង មានសិទ្ធិអាចត្រួតត្រាមើលភ្នាក់ងាររាជការដែលមានការៈរៀបរយការសាធារណៈ ឲ្យបំពេញកិច្ចដោយហ្មត់ចត់ ។ ប្រជាជនត្រូវពិនិត្យមើលភ្នាក់ងារៈរាជការម្នាក់ ៗ កុំឲ្យរំលោភលើពលរដ្ឋ ដូចស៊ីសំណូក ឬយកប្រាក់រាជការទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន ។

ពលរដ្ឋខ្មែរមានសិទ្ធិទាមទារឲ្យ រដ្ឋាភិបាលធ្វើការដើម្បីនឹងបន្ធូរបន្ថយសេចក្ដីលំបាករបស់ខ្លួន ។ យើងអាចទាមទារឲ្យរាជការសង់សាលាឬមន្ទីរពេទ្យឲ្យបានគ្រប់គ្រាន់ ថែរក្សាថ្នល់ឲ្យបានស្រួលបួល ហើយភ្នាក់ងាររាជការត្រូវបំរើប្រយោជន៍ប្រជារាស្ត្រពិតៗ មិនមែនបំរើប្រយោជន៍

ផ្ទាល់ខ្លួនទេ ។

ដែលនឹងធ្វើដូច្នេះបាន លុះត្រាតែប្រជាជនយើងរួមសាមគ្គីគ្នាដើម្បីនឹងឲ្យមានកម្លាំងស្រែក ជរាបដល់ភ្នាក់ងាររាជការយល់ថា រដ្ឋាភិបាលរបស់ប្រជាជន សម្រាប់ប្រជាជន នឹងដោយសារប្រជាជន ។

=-oo-=

# ២៦– ករណីយកិច្ចរបស់ប្រជាជននិង ករណីយកិច្ចរបស់អ្នកត្រួតត្រា

១ =ភ្នាក់ងាររាជការធ្វើការប្រយោជន៍អ្នកណា ?

២–ប្រយោជន៍ជាតិជាប្រយោជន៍របស់អ្នកណា ?

៣–បើសាធារណៈការជាការរបស់ប្រជាជនទាំងអស់ , ប្រជាជនត្រូវធ្វើម្ដេចខ្លះ ?

៤–អ្នករាជការដែលជាអ្នកបំពេញកិច្ចនេះត្រូវធ្វើយ៉ាងណា?

Z Z

Z

ករណីយកិច្ចរបស់ប្រជាជន– ករណីយកិច្ចរបស់ប្រជាជនគ្រប់រូបជាម្ចាស់ស្រុកមានគ្រាស់ក្រៃលណាស់ ។ ដំបូងបំផុតយើងត្រូវកាន់ចិត្ត ទីងអាកប្បកិរិយាជាពលរដ្ឋដ៏ពិតប្រាកដៗក្នុងឋានៈជាពលរដ្ឋ ប្រជាជនយើងកុំធ្វេសប្រហែសនូវសាធារណៈការដែលយើងប្រគល់ឲ្យទៅភ្នាក់ងាររាជ

ការនោះ ៗ យើងត្រូវពិនិត្យមើលជានិច្ចជាកាល ហើយ យើងត្រូវដឹងថាការជ្រើសតាំងអ្នកដំណាង យើងជាកិច្ចមួយសំខាន់ណាស់ ព្រោះវាសនារបស់ស្រុកយើងសម្រេចលើការចាត់តាំងនេះ ៗ ដូច្នេះយើងត្រូវប្រយ័ត្នឲ្យមែនទែននៅពេលបោះឆ្នោត ៗ គួរយើងទៅបោះឆ្នោតទាំងអស់គ្នា ហើយបោះឲ្យតែអ្នកណាដែលយើងទុកចិត្ត ៗ

ម្យ៉ាងទៀតយើងត្រូវយល់ថា ស្រុកណាមួយដែលមានដម្លៃលុះត្រាតែអ្នកស្រុកនោះមានដម្លៃដែរ គឺថាត្រូវតែពលរដ្ឋបេះពិចារណា, ស្វែងរកសេចក្ដីខុសត្រូវ រកពន្លឺដើម្បីទឹងជួយញ៉ាំងឬណែនាំដោយការទិទៀនតាមកាសែត នូវការងារជាសាធារណៈទាំងឡាយ ឲ្យបានជឿនលឿនទៅមុខ ៗ ដូច្នេះពលរដ្ឋយើងម្នាក់ៗមានករណីយកិច្ចត្រូវសង្វាតបំភ្លឺបញ្ញារបស់ខ្លួនដោយខំរៀនខំពិចារណា ទឹងខំស្ទុះក្ដៅក្នុងការពង្រីកប្រជាសិក្សា ៗ

ពលរដ្ឋទាំងអស់ត្រូវកាន់ចិត្តយោគយល់គ្នា ចងសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក ដើម្បីយកកម្លាំងពង្រីញ ស្រុកឲ្យទៅកាន់វឌ្ឍនធម៌ ។ ការគោរពច្បាប់ជាករណីយកិច្ចមួយធំបន្ថស់ៗច្បាប់នេះហើយ ដែលជាគ្រឿងការពារប្រយោជន៍ទូទៅជួនកាលច្បាប់មិនស្របនឹងប្រយោជន៍បុគ្គលខ្លះដែរ តែពលរដ្ឋភាគនោះគួរប្តេជ្ញា កាត់ប្រយោជន៍ផ្ទាល់ខ្លួនពេលខ្លះដើម្បីប្រយោជន៍ជាសាធារណៈវិញ ។

ជាទីបំផុត បើយើងចង់ឲ្យការសាធារណៈ យើងមានដំណើរទៅស្រួលគួរយើងជួយបង់ពន្ធតាមច្បាប់បញ្ញត្តិ ។ បើប្រាក់ពន្ធមិនចូល ការសាធារណៈក៏មិនដើរដែរ គួរយើងចាំថាយើងបង់ពន្ធ មិនមែនឲ្យភ្នាក់ងាររាជការដេកស៊ីស្រណុកទេ គឺឲ្យធ្វើការជាប្រយោជន៍ស្រុក ។

ករណីយកិច្ចរបស់អ្នកត្រួតត្រា — ដូច្នេះភ្នាក់ងាររាជការដែលជាអ្នកត្រួតត្រានោះ មានករណីយកិច្ចត្រូវបំពេញ

សាធារណៈប្រយោជន៍ ដើម្បីឲ្យបានផលជូនដល់ប្រជាជនគ្រប់ៗគ្នាមិនប្រកាន់ថាជានរណាៗឡើយ ។ ត្រូវរកមធ្យោបាយដើម្បីសម្រួលជីវភាពរបស់ប្រជាជនបន្តិចម្តងៗ ទើបហៅថាភ្នាក់ងាររាជការពិតត្រង់ ។ ក្រសួងពេទ្យត្រូវតែយកចិត្តទុកដាក់មើលជម្ងឺប្រជាជនខ្មែរទាំងអស់មិនរើសមុខ គិតធ្វើដូចម្តេចឲ្យជម្ងឺនោះអន់ថយឈប់រាតត្បាតអ្នកស្រុកទៀត ។ គ្រូបង្រៀនក៏ដូច្នោះដែរ ត្រូវខំបង្កើនវប្បធម៌ជាតិឲ្យបានជឿនទៅមុខ; ពាហានត្រូវថែរក្សាសន្តិសុខដល់ប្រជាជន ។ ដូច្នោះករណីយកិច្ចរបស់អ្នកត្រួតត្រា គឺត្រូវធ្វើការឲ្យជាប្រយោជន៍សាធារណៈ ។

=-១០-=

# ២៧- ស្នេហាជាតិ

១- អ្នកស្រឡាញ់ភូមិកំណើតអ្នកឬទេ? ព្រោះអ្វី?

២-អ្នកស្រឡាញ់ប្រទេសកម្ពុជា ដែលជាប្រទេសអ្នកឬទេ?

៣- បើអ្នកស្រឡាញ់ស្រុកអ្នក អ្នកត្រូវធ្វើយ៉ាងណាខ្លះ ដើម្បីបង្ហាញឲ្យឃើញថាអ្នកស្រឡាញ់ពិតមែន?

៤-បើអ្នកស្រឡាញ់ស្រុកអ្នក, ជនឯទៀតគេក៏ស្រឡាញ់ស្រុកគេដែរ តើយើងធ្វើយ៉ាងណាកុំឲ្យទាស់ទែងគ្នា?

Z Z

Z

ស្រុកយើងគឺជាទឹកដីរបស់ដូនជីតាយើង ជាទឹកដីរបស់យើងផង ជាទីកន្លែងដែលយើងកើត ដែលយើងរស់នៅដោយមានសិទ្ធិគ្រប់យ៉ាង ៗ របស់អ្វីដែលនៅទីនេះជារបស់យើងទាំងអស់ អ្នកស្រុកក៏ជាញាតិរបស់យើងដែរ ៗ ដោយហេតុនេះ បានជាយើងត្រូវស្រឡាញ់ស្រុកយើងដូចជា

ឃើញស្រឡាញ់ផ្ទះយើងដែរ ។

ដែលហៅថាអ្នកស្រឡាញ់ស្រុកពិតនោះ គឺអ្នកណាដែលចំការពារព្រំដែន ទឹកដីរបស់ស្រុក ដែលចំធ្វើការម៉ឺនម៉ាត់ ដើម្បីកសាងស្រុកខ្លួនឲ្យទៅកាន់ឋានៈសមរម្យទឹងគេខាងផ្លូវសេដ្ឋកិច្ចក៏ដោយ ខាងផ្លូវនយោបាយក៏ដោយ ខាងផ្លូវសង្គមកិច្ចក៏ដោយ គឺចំផ្គត់ផ្គង់ឲ្យស្រុកយើងមានផ្លូវគមនាគមន៍ មានមន្ទីរពេទ្យ មានសាលារៀនគ្រប់គ្រាន់ឡើង តាមសេចក្ដីត្រូវការរបស់ប្រជាជន យកលទ្ធផលនោះមកចែកចាយឲ្យបានគ្រប់គ្រាន់ដល់ប្រជាជន កុំឲ្យអ្នកខ្លះមានពេកអ្នកខ្លះក្រពេក ។

ភារៈរបស់អ្នកជាកុមារកុមារីនោះ គឺត្រូវតែស្រឡាញ់គ្នាដូចបងប្អូនជួយជាស់តឿនគ្នាឲ្យចំរៀន ដើម្បីកសាងស្រុកដល់វេលាអ្នកធំឡើង ៗ ត្រូវអ្នកដឹងថាដែលស្នេហាជាតិមែនទែននោះ មិនមែនមានសេចក្ដីងងឹតឃើញតែស្រុកឯងល្អជាង

គេនោះទេ មិនមែនអួតតែស្រុកឯងថាខ្លាំងពូកែជាងគេនោះទេ យើងត្រូវយល់ថាស្រុកណាក៏ដោយក្នុងលោកក៏ដូចជាមនុស្សម្នាក់ៗដែរត្រូវការគ្នាទៅវិញទៅមកជៀសមិនរួចៗ ស្រុកខ្មែរទុកជាដូចម្ដេចក៏ត្រូវការលក់អីវ៉ាន់ឲ្យស្រុកយួន ត្រូវទិញស្រូវពីស្រុកសៀម លក់ត្រីទៅឲ្យស្រុកសៀមវិញ ត្រូវការទិញសៀវភៅពីស្រុកបារាំងនិងស្រុកផ្សេងៗទៀតពុំខានៗ ដូច្នេះកា.ស្នេហាជាតិមិនមែនលះបង់នូវសេចក្ដីសាមគ្គីឡើយ ផ្ទុយទៅវិញ សេចក្ដីស្នេហាជាតិមែនទែននោះស្របនឹងសេចក្ដីយោគយល់និងសាមគ្គីធម៌ៗ

=ooo=

## ២៨-- ត្រូវជៀសវាងចម្បាំងរាំងជល់

១–សួរលោកគ្រូអ្នកមើលពេលចម្បាំងម្តង ៗ លំបាកយ៉ាងណាខ្លះ?

២–សួរលោកមើល តើគ្រាប់បែកជាគ្រឿងអាវុធមួយកាចយង់ឃ្នងយ៉ាងណា? សុំឲ្យគាត់បង្ហាញរូបថតកន្លែងដែលគ្រាប់បែកធ្លាក់ក្នុងពេលចំបាំងណាមួយមើល ៗ

៣– សួរលោកគ្រូអ្នកមើល តើកម្លាំងគ្រាប់បែកសម័យឥឡូវខ្លាំងយ៉ាងណា?

៤–ចុះបើគេប្រើគ្រាប់បែកនេះ ១ គ្រាប់ តើប្រជាជនស្លាប់ចំនួនប៉ុន្មាន?

Z Z

Z

ស្រុកនិមួយ ៗ ដូចជាមនុស្សយើងម្នាក់ ៗ ដែរ ត្រូវតែរកសេចក្តីសុខដោយសម្រួលការពាក់ទងរវាងគ្នានិងគ្នា ។

ប្រទេសនីមួយៗ បើមិនព្រមស្គាល់តម្លៃសាមគ្គីធម៌រវាងគ្នានឹងគ្នាទេ មុខជាកើតសង្គ្រាមមិនខានឡើយ ។

យើងត្រូវដឹងថា សង្គ្រាមជាអំពើឃោរឃៅបំផុតរបស់មនុស្សលោកយើង ។ សង្គ្រាមម្ដងៗ សម្លាប់មនុស្សច្រើននាក់ បំផ្លាញរបស់ទ្រព្យអស់ច្រើនណាស់ ។ ផ្ទះល្អៗផេះដោយគ្រាប់បែក ផ្លូវថ្នល់,ស្ពានដាច់ដាចអស់ សាលា មន្ទីរពេទ្យរលំជាច្រើន ។ អំពើនេះហើយនាំឲ្យមនុស្សសោយទុក្ខគ្រប់យ៉ាង មានព្រាត់ប្រាសញាតិសន្ដាន នឹងការអត់ឃ្លានជាដើម ។ សេចក្ដីភិតភ័យក៏មកគ្របសង្កត់លើប្រជាជនគ្រប់ៗគ្នា ។

មួយទៀតក្នុងពេលឥឡូវនេះ គេមានអាវុធយ៉ាងបំណានៗ ដូចគ្រាប់បែកបរមាណូជាដើម អាចប្រហារជីវិតស្រុកមួយទាំងមូលក៏បានដែរ ។ នេះគួរឲ្យខ្លាចណាស់ ។

ដូច្នេះយើងត្រូវរិះរកមធ្យោបាយ ដើម្បីនឹងរាំងរាកុំឲ្យសង្គ្រាមកើតឡើងបាន ។ សង្គ្រាមនេះមិនចេះផ្ដល់កម្រៃ

ផលល្អដល់អ្នកណាមួយឡើយ ។ អ្នកឈ្នះក៏ដូចអ្នកចាញ់ តែងតែស្គាល់ទុក្ខវេទនាទាំងអស់ ដូចមានចំបាំងសាកល លើកទី២នេះជាសាក្សីស្រាប់ ៗ ពេលនោះគ្រាប់បែកសម្លាប់ មនុស្សជាច្រើនលាន បំផ្លាញស្រុកទាំងមូល ៗ ស្រុកខ្លះនើប ពីទុក្ខមិនទាន់បានស្រឡះផង ៗ

នៅចម្បាំងទី២

ស្រុកបារាំងបានបង់ខាតទាហាន ១៣០.០០០ នាក់

| | | | |
|---|---|---|---|
| –រុស្ស៊ី | ” | ១៣.៤០០.០០០ | នាក់ |
| –អាល្លឺម៉ង់ | ” | ៨.០០០.០០០ | នាក់ |
| –អង់គ្លេស | ” | ៣៨០.០០០ | នាក់ |
| –ស.ហ.អា. | ” | ២៩៧.០០០ | នាក់ |
| –ប៉ូឡូញ | | ៩០០.០០០ | ” |

ខាងស៊ីវិល ៖

–បារាំងបង់ខាតអស់ ១០០.០០០ នាក់

| | | |
|---|---|---|
| -ប៉ូឡូញ | ៥០០០ ០០០ | នាក់ |
| -រុស្ស៊ី. | ច្រើនលាន | - |

នៅមានស្រុកច្រើនទៀត ដែលគេមិនអាចដឹងចំនួនមនុស្ស ស្លាប់ប្តូរប្រួសបាន ។

=០០០=

# ២៩- សហប្រជាជាតិ

១- តើប្រទេសខ្មែរយើងបានចូលសហប្រជាជាតិពីកាលណា ?

២- សួរលោកគ្រូមើលសហប្រជាជាតិនេះជាអ្វី ? នៅឯណា ?

៣- នៅទីនោះគេធ្វើអ្វីខ្លះ ?

៤- សុំឲ្យលោកគ្រូអ្នកបង្ហាញទង់ជ័យ ដំណាងសហប្រជាជាតិមើល ។

Z Z

Z

ប្រទេសនិមួយ ៗ ក្នុងលោកត្រូវតែមានសាមគ្គីធម៌រួបរួមគ្នាទៅវិញទៅមក ទើបរស់នៅបានក្នុងពេលឥឡូវនេះ ។ កាលបើសាមគ្គីនេះបាក់បែកហើយ មុខជានឹងកើតសង្គ្រាមមិនខាន ។ ដោយប្រជាជនគ្រប់សាសន៍ស្គាល់អំពើមហន្តរាយនៃសង្គ្រាម ទើបបបួលគ្នាបង្កើតអង្គការអន្តរជាតិផ្សេង ៗ

ដើម្បីសម្រួលការវិវាទតាមសន្តិវិធី ដើម្បីជៀសវាងការប្រើប្រាស់កម្លាំងយោធា ។

ដូច្នេះហើយបានជាគេ ចំក្រងច្បាប់សំរាប់ប្រើខាងផ្លូវអន្តរជាតិ ដូចជាច្បាប់កាកបាទក្រហមអន្តរជាតិ ស្តីពីរបៀបជួយគ្នាក្នុងពេលមានទុក្ខភ័យ ។

ច្បាប់សង្គ្រាមស្តីពីរបៀបប្រើអាវុធ ។

តុលាការអន្តរជាតិឋិតនៅក្រុង «ឡាហេ» សំរាប់កាត់ក្តីចំពោះការទាស់ទែងរវាងប្រទេសនីមួយ ៗ ។

ក្រោយពេលចំបាំងសាកលលោកលើកទី ១ គេបានបង្កើត«សមាគមអន្តរជាតិ» ដែលមានប្រទេស ៥៤ ចូលជាសមាជិក ។ សមាគមនេះបានប្រជុំគ្នាជាញឹកញយ ដើម្បីទឹងដោះស្រាយបញ្ហារវាងប្រទេសនឹងប្រទេស តែដោយខ្សោយកម្លាំងពេក សមាគមនេះក៏រលំទៅវិញនៅឆ្នាំ១៩៣៩ ហើយសង្គ្រាមសាកលលោកលើកទី ២ ក៏ផ្ទុះឡើង ។

ជល់ចុងសង្គ្រាមលើកទី២នេះ ប្រទេសទាំងឡាយក៏ព្រមគ្នាបង្កើតអង្គការមួយទៀតហៅថា៖ សហប្រជាជាតិ ដែលនគរខ្មែរយើងជាសមាជិកមួយដែរ ។ គោលបំណងរបស់សហប្រជាជាតិគឺ៖

ការពារសន្តិភាពក្នុងលោក ;

កសាងមិត្តភាពរវាងប្រទេសនឹងប្រទេស;

ចាត់វិធានការណ៍ផ្សេងៗដើម្បីពង្រីកសន្តិភាព;

ប្រតិបត្តិសហការដើម្បីនឹងដោះស្រាយបញ្ហាខាងសេដ្ឋកិច្ច ខាងសង្គមកិច្ច នឹងខាងវប្បធម៌ ។

ទុកខ្លួនជាមជ្ឈដ្ឋានមួយដើម្បីចម្រុះការប្រឹងប្រែងគ្រប់ប្រទេសនានា ទៅកាន់នូវគោលបំណងខាងលើនេះ ។

០ ចប់ ០

# បញ្ជីរឿង

ទំព័រ

អារម្ភកថា ........ ក

តើបង្រៀនលោកនីតិយ៉ាងដូចម្ដេច ........ ១

១= ត្រូវប្រយ័ត្នតាមផ្លូវ ........ ១១

២= សហករណ៍ ........ ១៤

៣= អំពីឃុំនិងភូមិ ........ ១៨

៤= មេឃុំនិងសហការី ........ ២០

៥= អគ្គានុកូលដ្ឋាន ........ ២៣

៦= ស្រុកនិងខេត្ត ........ ២៦

៧= ស្រុកខ្មែរ ........ ២៩

៨= រដ្ឋសភា ........ ៣៣

៩= ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ........ ៣៧

១០- អំណាចនីតិប្រតិបត្តិ ........ ៤១

១១- អំណាចតុលាការ ........ ៤៥

១២– ហេតុអ្វីបានជាគេចែកអំណាចជាបី ..... ៤៨

១៣– សភាប្រជារាស្រ្តប្រចាំខេត្តនឹងប្រចាំរាជធានី ..... ៥១

១៤– ការបោះឆ្នោត ..... ៥៤

១៥– តើគេបោះឆ្នោតយ៉ាងដូចម្ដេច ..... ៥៨

១៦– ច្បាប់ ..... ៦២

១៧– រដ្ឋបាល ..... ៦៦

១៨– ក្រសួងសិក្សាធិការជាតិ ..... ៦៩

១៩– ក្រសួងសាធារណការ ..... ៧២

២០– ក្រសួងយុត្តិធម្ម ..... ៧៦

២១– សាលាវិនិច្ឆ័យ ..... ៧៩

២២= ក្រសួងការពារប្រទេស ..... ៨២

២៣- ច្បាប់ព្រហ្មទណ្ឌនឹងច្បាប់រដ្ឋប្បវេណី ..... ៨៦

២៤= ចរិកាជាតិ ..... ៨៩

២៥= សិទ្ធិរបស់ប្រជាជន ..... ៩៣

២៦ ករណីកិច្ចរបស់ប្រជាជននឹងករណីកិច្ចរបស់អ្នកត្រួតត្រា ៩៧

២៧= ស្នេហាជាតិ ............ ១០១

២៨= ត្រូវជៀសវាងចម្បាំងកំងផល់ ............ ១០៤

២៩= សហប្រជាជាតិ ............ ១០៨

XXXXX

ផ្ទះលេខ ១៣៥ មហាវិថីព្រះ

តម្លៃ ១៨ រៀល